ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំយុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ

កិច្ចស្រាវជ្រាវ

# គណិតវិទ្យា

# ម៉ាទ្រីស និង ដេទែមីណង់






រៀបរៀងដោយៈ សេង សុភាសិត

គរុនិស្សិតគណិតវិទ្យាក្រុម២ ជំនាន់ទី១៨ ឆ្នាំសិក្សា ២០១២-២០១៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំយុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ

សៀវភៅកិច្ចការស្រាវជ្រាវគណិតវិទ្យា មេរៀន និង លំហាត់
សម្រាប់គ្រូ និងសិស្ស មធ្យមសិក្សាទុតិយភូមិ

# ម៉ាទ្រីស និងដេទែមីណង់


គរុនិស្សិតគណិតវិទ្យាក្រុម២ ជំនាន់ទី ១៨

សេង សុតាសិត

សេង រដ្ឋា

កៅ សេដា

ម៉ៅ មាន

អ៊ុំ សាន

សៅ អឿន

កែវ សុវណ្ណារ៉ា

ឈួន ឈៀង

ង៉ាក កែម

សាស្ត្រាចារ្យណែនាំ: ថៃ ហេង


ឆ្នាំសិក្សា ២០១២-២០១៣

# អារម្ភកថា

សៀវភៅកម្រងស្រាវជ្រាវគណិតវិទ្យាសម្រាប់ជំនួយដល់ការសិក្សា និងជាឯកសារស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងបន្ថែមលើមុខវិជ្ជាគណិតវិទ្យាខាងផ្នែក ម៉ាទ្រីស និងដេទែមីណង់ ។ ការរៀបចំឲ្យមានកិច្ចការស្រាវជ្រាវនេះឡើង គឺក្នុងគោលបំណងពង្រឹងនិងពង្រីកសមត្ថភាពបន្ថែមទៅលើផ្នែកគណិតវិទ្យា ដល់គរុនិស្សិតជំនាន់ទី១៨ នៃវិទ្យាស្ថានជាតិអប់រំ ផ្នែកដេប៉ាតេម៉ង់ គណិតវិទ្យាទាំងមូលទៅលើគ្រប់ផ្នែក នៃគណិតវិទ្យា និងបានបែងចែកជាក្រុមក្នុងការស្រាវជ្រាវ ។ សៀវភៅកិច្ចការស្រាវជ្រាវនេះផ្តោតសំខាន់ទៅលើផ្នែកម៉ាទ្រីស និងដេទែមីណង់ ។ ខ្លឹមសារមេរៀនត្រូវបានសង្ខេបគន្លឹះសំខាន់ៗព្រមទាំងមានឧទាហរណ៍បញ្ជាក់ ដែលមានសម្រាយងាយយល់ ។ ក្នុងសៀវភៅនេះរួមមានលំហាត់បន្ថែម ព្រមទាំងដំណោះស្រាយ ងាយយល់ និងក្បោះក្បាយ ។ យើងខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងអាចជួយដល់កង្វះខាតខ្លះៗ របស់ប្អូនៗ និងមិត្តអ្នកអានក្នុងការស្រាវជ្រាវលើផ្នែកគណិតវិទ្យានេះ ហើយនិងអាចផ្តល់នូវចំណេះដឹងថ្មីៗដល់មិត្តអ្នកអានព្រមទាំងជួយ ដល់សិស្ស និស្សិត និងមិត្តអ្នកអានគ្រប់រូបផងដែរ ។

សូមអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គង ដែលបានកើត មានឡើងដោយចេតនាក្តីដោយអចេតនាក្តី ហើយនឹងទទួលនូវមតិ រិះគន់ដើម្បីស្តាបនាពីមិត្តអ្នកអានទាំងអស់ដោយសេចក្តីរីករាយបំផុត ដើម្បីឲ្យសៀវ ភៅកិច្ចការស្រាវជ្រាវនេះកាន់តែប្រសើរ យើងខ្ញុំនឹងទទួលរាល់ការរិះគន់ដើម្បីកែសម្រួលបន្ថែមអំពី សំណាក់អ្នកអាន ជាពិសេសលោកគ្រូអ្នកគ្រូបញ្ញាវន្តសិក្សាលើផ្នែកគណិតវិទ្យានេះឲ្យកាន់តែមានគុណភាព ។

សូមថ្លែងអំណរគុណដល់មាតា បីតា គ្រប់រូបដែលបានខិតខំបីបាច់ថែរក្សាកូនចៅ និងបណ្តុះបណ្តាលចំណេះវិជ្ជា ជាពិសេសវិទ្យាស្ថានជាតិអប់រំដែលបានខិតខំបណ្តុះបណ្តាលនូវគរុនិស្សិតដែលសុទ្ធសឹងតែមានសមត្ថភាព និងចំណេះដឹងពិតៗ ។

សូមជូនពរប្អូនៗ សិស្ស និស្សិត ព្រមទាំង មិត្តអ្នកអានទាំងអស់គ្នា ជួបប្រទះតែសេចក្តីសុខចម្រើន មានសុខភាពល្អ ប្រាជ្ញាវៀងវៃ និងសូមឲ្យទទួលបាននូវលទ្ធផលល្អ តាមដែលខ្លួនប៉ងប្រាថ្នារៀងៗខ្លួន ។

**រៀបរៀងដោយ**

គរុនិស្សិតគណិតវិទ្យាក្រុម២

# មាតិកា

## ម៉ាទ្រីស


1. សញ្ញាណនៃម៉ាទ្រីស ........ 1
1.1. និយមន័យ ........ 1
1.2. ប្រភេទម៉ាទ្រីស ........ 2
2. ប្រមាណវិធីលើម៉ាទ្រីស ........ 3
2.1. ម៉ាទ្រីសស្មើគ្នា ........ 3
2.2. វិធីបូក និង វិធីដកនៃម៉ាទ្រីស ........ 3
2.3. ផលគុណមួយចំនួនពិតនឹងម៉ាទ្រីស ........ 3
2.4. វិធីគុណនៃពីរម៉ាទ្រីស ........ 4
3. ទម្រង់ម៉ាទ្រីសនៃប្រព័ន្ធសមីការលីនេអ៊ែរ ........ 5
4. ម៉ាទ្រីសត្រង់ស្ប៉ូ ........ 6
5. ចំរាសនៃម៉ាទ្រីសការេ ........ 7
6. ម៉ាទ្រីសស្វ័យគុណ ........ 9
7. លក្ខណៈនៃម៉ាទ្រីសត្រង់ស្ប៉ូ ........ 9
8. ម៉ាទ្រីសស៊ីមេទ្រី ........ 10


## ដេទែមីណង់


1. អនុគមន៍ដេទែមីណង់ ........ 11
2. ដេទែមីណង់លំដាប់ 2 ........ 11
3. ដេទែមីណង់លំដាប់3 ........ 11
3.1 គណនាដេទែមីណង់លំដាប់ 3 តាមក្បួនរបស់សារុស ........ 11
3.2 គណនាដេទែមីណង់លំដាប់ 3 តាមមីន័រ ........ 12
4. ដោះស្រាយប្រព័ន្ធសមីការលីនេអ៊ែរ ........ 12
4.1. ទម្រង់ម៉ាទ្រីសនៃប្រព័ន្ធសមីការលីនេអ៊ែរ ........ 12
4.2. ដោះស្រាយប្រព័ន្ធសមីការតាមក្រាមែរ ........ 13
4.3. ដោះស្រាយប្រព័ន្ធសមីការតាម (*Guass – Jordan*) ........ 14

4.4. ដោះស្រាយប្រព័ន្ធសមីការតាមចម្រាសនៃម៉ាទ្រីស ..........15

**ផ្នែកលំហាត់** ..........17

**ផ្នែកដំណោះស្រាយ** ..........23

# ឯកសារយោង


1. Elementary Linear Algebra-Howard Anton-6 Edition
2. Linear Algebra "J. Henderson" (University of Sydney)
3. Algébre: tome 2 "Guy Auliac"
4. MathématiQues: DEUG – SCiENCES
5. សៀវភៅ ១៥ ភាគ មេរៀនម៉ាទ្រីស និងដេទែមីណង់
6. សៀវភៅគណិតរបស់ក្រសួងអប់រំយុវជន និង កីឡា

# ម៉ាទ្រីស (*Matric*)

## 1. សញ្ញាណនៃម៉ាទ្រីស (*Matrices Nation*)

### 1.1. និយមន័យ

*ម៉ាទ្រីស* គឺជាការរៀបលេខ ឬចំនួនជារាងចតុកោណកែង ឬ ការរេនៅក្នុងសញ្ញាដង្កៀប [ ] ។ យើងតាងម៉ាទ្រីសដោយអក្សរធំ $A,B,C,...$ ។ លេខ ឬ ចំនួន ដែលគេរៀបនេះហៅថា **ធាតុ** (*Entries*) នៃម៉ាទ្រីសដែលកំណត់តាងធាតុម៉ាទ្រីសដោយអក្សរតូច $a,b,c,...$ សម្រាប់តាងឲ្យបរិមាណជាលេខ ។

**ឧទាហរណ៍** គេមានម៉ាទ្រីសលំដាប់ $2\times 3$ ( អានថា 2 ខ្វែង 3 ) ដូចខាងក្រោម ៖

ជួរឈរទី 1 ជួរឈរទី 2 ជួរឈរទី 3

$$A=\begin{bmatrix} 2 & 1 & 7 \\ 3 & 4 & 2 \end{bmatrix}$$

← ជួរដេកទី 1

← ជួរដេកទី 2

| |
|---|
| **ជាទូទៅ** ម៉ាទ្រីស គឺជាការរៀបចំនួនជារាងចតុកោណកែង ឬការរេដាក់ក្នុងសញ្ញាដង្កៀប [ ] ។ គេកំណត់តាងម៉ាទ្រីសដោយអក្សរធំដូចជា $A,B,C,...$ និងធាតុនៃម៉ាទ្រីសតាងដោយអក្សរតូច $a,b,c,...$ ។ ម៉ាទ្រីស $A$ មានលំដាប់ $m\times n$ កំណត់ដោយ: $$A=\underbrace{\begin{bmatrix} a_{11} & a_{12} & a_{13} ...a_{1n} \\ a_{21} & a_{22} & a_{33}... \ a_{2n} \\ a_{31} & a_{32} & a_{33}... \ a_{3n} \\ \vdots & \vdots & \vdots \quad \vdots \\ a_{m1} & a_{m2} & a_{m3}...a_{mn} \end{bmatrix}}_{n} \left.\vphantom{\begin{matrix}1\\1\\1\\1\\1\end{matrix}}\right\} m$$ |

- ម៉ាទ្រីស $n$ ដែលមាន $n$ ជួរដេក និង $n$ ជួរឈរហៅថា **ម៉ាទ្រីសការេលំដាប់** $n$ (*Square Matrix of Order* $n$ ) ហើយធាតុ $a_{11}, a_{22}, ...a_{nn}$ ហៅថា **ធាតុអង្កត់ទ្រូងសំខាន់** (*Main Diagonal Entries*) នៃម៉ាទ្រីស $A$ កំណត់ដោយ:

$$A=\begin{bmatrix} a_{11} & a_{12} & a_{13} ...a_{1n} \\ a_{21} & a_{22} & a_{33}... \ a_{2n} \\ a_{31} & a_{32} & a_{33}... \ a_{3n} \\ \vdots & \vdots & \vdots \quad \vdots \\ a_{n1} & a_{n2} & a_{n3}...a_{nn} \end{bmatrix}$$

- ម៉ាទ្រីសការេ ដែលមានធាតុទាំងអស់ស្មើសូន្យ លើកលែងតែធាតុអង្កត់ទ្រូងសំខាន់ នោះហៅថា **ម៉ាទ្រីសអង្កត់ទ្រូង** $(Diagonal\ Matrix)$ កំណត់សេរសេរដោយ:

$$A=\underbrace{\begin{bmatrix} a_{11} & 0 & 0 & \dots & 0 \\ 0 & a_{22} & 0 & \dots & 0 \\ 0 & 0 & a_{33} & \dots & 0 \\ \vdots & \vdots & \vdots & & \vdots \\ 0 & 0 & 0 & \dots & a_{mn} \end{bmatrix}}_{n} \left.\vphantom{\begin{bmatrix} a \\ a \\ a \\ a \\ a \end{bmatrix}}\right\} m$$

**1.2.** ប្រភេទម៉ាទ្រីស

ក. ម៉ាទ្រីសសូន្យ

ម៉ាទ្រីសសូន្យ គឺជាម៉ាទ្រីសដែលមានធាតុទាំងអស់ស្មើសូន្យ គេកំណត់តាងដោយ $O$ ។

$O=\begin{bmatrix} 0 & 0 \\ 0 & 0 \end{bmatrix}$ ; $O=\begin{bmatrix} 0 & 0 \end{bmatrix}$ ; $O=\begin{bmatrix} 0 \\ 0 \\ 0 \end{bmatrix}$ ; $O=\begin{bmatrix} 0&0&0&0 \\ 0&0&0&0 \\ 0&0&0&0 \end{bmatrix}$

លំដាប់ $2\times2$ លំដាប់ $1\times2$ លំដាប់ $3\times1$ លំដាប់ $3\times4$

ខ. ម៉ាទ្រីសការេ

$A=\begin{bmatrix} 3 & 9 \\ -4 & 6 \end{bmatrix}$ មាន $2$ ជួរដេក និង $2$ ជួរឈរ គេថា**ម៉ាទ្រីសការេលំដាប់** $2$ ។

$A=\begin{bmatrix} 2 & 8 & 0 \\ -2 & 1 & 3 \end{bmatrix}$ មាន $2$ ជួរដេក និង $3$ ជួរឈរ គេថា **ម៉ាទ្រីសការេលំដាប់** $3$ ។

**ជាទូទៅ** ម៉ាទ្រីសការេ ជាម៉ាទ្រីសមានចំនួនជួរដេកស្មើនឹងចំនួនជួរឈរ តាងដោយ

$$A=\begin{bmatrix} a_{11} & a_{12} & a_{13} \dots a_{1n} \\ a_{21} & a_{22} & a_{33} \dots a_{2n} \\ a_{31} & a_{32} & a_{33} \dots a_{3n} \\ \vdots & \vdots & \vdots \quad \vdots \\ a_{n1} & a_{n2} & a_{n3} \dots a_{nn} \end{bmatrix}$$ ហៅថា **ម៉ាទ្រីសការេលំដាប់** $n$ ។

គ. ម៉ាទ្រីសឯកតា

ម៉ាទ្រីសការេដែលធាតុនៅលើអង្កត់ទ្រូងពិសេស $a_{11}=a_{22}=a_{33}=\dots=a_{nn}=1$ ហើយធាតុផ្សេងទៀតស្មើនឹងសូន្យ ហៅថា ម៉ាទ្រីសឯកតាតាងដោយ $I$ ។

ឧទាហរណ៍: ម៉ាទ្រីសខាក្រោមសុទ្ធតែជាម៉ាទ្រីសឯកតា

$I=\begin{bmatrix}1 & 0\\ 0 & 1\end{bmatrix}$ លំដាប់ $2\times2$ ; $I=\begin{bmatrix}1 & 0 & 0\\ 0 & 1 & 0\\ 0 & 0 & 1\end{bmatrix}$ លំដាប់ $3\times3$ ; $I=\begin{bmatrix}1 & 0 & 0 & 0\\ 0 & 1 & 0 & 0\\ 0 & 0 & 1 & 0\\ 0 & 0 & 0 & 1\end{bmatrix}$ លំដាប់ $4\times4$

## 2. ប្រមាណវិធីលើម៉ាទ្រីស

### 2.1. ម៉ាទ្រីសស្មើគ្នា

ម៉ាទ្រីសពីរស្មើគ្នាកាលណា ម៉ាទ្រីសទាំងពីរមានលំដាប់ដូចគ្នានិងមានធាតុត្រូវគ្នាស្មើរៀងគ្នា ។

**ឧទាហរណ៍** គេមានម៉ាទ្រីស $A=\begin{bmatrix}2 & 9 & 0\\ 3 & 4 & 0\end{bmatrix}$, $B=\begin{bmatrix}b_{11} & b_{12} & b_{13}\\ b_{21} & b_{22} & b_{23}\end{bmatrix}$ មានលំដាប់ $2\times3$ ដូចគ្នា ។

ម៉ាទ្រីស $A$ ស្មើម៉ាទ្រីស $B$ កាលណា $b_{11}=2; b_{12}=9; b_{13}=0; b_{21}=3; b_{22}=4; b_{23}=0$ ។ ម៉ាទ្រីស $A$ ស្មើនឹងម៉ាទ្រីស $B$ គេសរសេរដោយ: $A=B$ ។

### 2.2 វិធីបូក និង វិធីដកនៃម៉ាទ្រីស

**និយមន័យ** បើ $A$ និង $B$ ជាម៉ាទ្រីសពីរដែលមានលំដាប់ដូចគ្នា នោះផលបូក $A+B$ ជាម៉ាទ្រីសដែលបានមកដោយការបូកនូវធាតុដែលត្រូវគ្នាក្នុងម៉ាទ្រីសទាំងពីរ ។ ម៉ាទ្រីសដែលមានលំដាប់ខុសគ្នាមិនអាចធ្វើប្រមាណវិធីបូកបានទេ ។

**និយមន័យ** បើ $A$ និង $B$ ជាម៉ាទ្រីសពីរដែលមានលំដាប់ដូចគ្នា នោះផលដក $A-B$ ជាម៉ាទ្រីសដែលបានមកដោយការដកនូវធាតុដែលត្រូវគ្នាក្នុងម៉ាទ្រីសទាំងពីរ ។ ម៉ាទ្រីសដែលមានលំដាប់ខុសគ្នាមិនអាចធ្វើប្រមាណវិធីដកបានទេ។

### 2.3 ផលគុណរវាងចំនួនពិតនឹងម៉ាទ្រីស

**ជាទូទៅ** បើគេមានចំនួនពិត $k$ និងម៉ាទ្រីស $A$ នោះម៉ាទ្រីស $A\cdot k$ បានដោយគុណធាតុនីមួយៗនៃម៉ាទ្រីស $A$ នឹងចំនួនពិត $k$ ។

បើ $A=\begin{bmatrix}a & b\\ c & d\end{bmatrix}$ នោះ $k\cdot A=k\cdot A=k\cdot\begin{bmatrix}a & b\\ c & d\end{bmatrix}=\begin{bmatrix}a & b\\ c & d\end{bmatrix}\cdot k=\begin{bmatrix}ka & kb\\ kc & kd\end{bmatrix}$ ។

- លក្ខណៈផលបូក ផលដក និងផលគុណស្កាលែ

បើ $A, B$ និង $C$ ជាម៉ាទ្រីសមានលំដាប់ $m\times n$ និង $c, d$ ស្កាលែគេបាន:

១) $A+B=B+A$ លក្ខណៈត្រលប់នៃផលបូកម៉ាទ្រីស

២) $A+(B+C)=(A+B)+C$ លក្ខណៈផ្តុំនៃផលបូកម៉ាទ្រីស

៣) $(cd)A=c(dA)$ លក្ខណៈផ្តុំនៃផលគុណស្កាលែ

៤) $1\cdot A=A\cdot 1=A$ លក្ខណៈស្កាលែឈឹត

៥) $c(A\pm B)=cA\pm cB$ លក្ខណៈបំបែកនៃផលគុណស្កាលែចំពោះវិធីបូកឬវិធីដកម៉ាទ្រីស

៦) $(c\pm d)A=cA\pm dA$ លក្ខណៈបំបែកនៃផលគុណម៉ាទ្រីសចំពោះវិធីបូកឬវិធីដកស្កាលែ

## 2.4. វិធីគុណនៃពីរម៉ាទ្រីស

**និយមន័យ** ម៉ាទ្រីសពីរគុណគ្នាបានលុះត្រាតែ ចំនួននៃជួរឈរម៉ាទ្រីសទីមួយស្មើនឹងចំនួនធាតុនៃជួរដេកម៉ាទ្រីសទីពីរ ។

**ជាទូទៅ** បើ $A=\left[a_{ij}\right]$ ជាម៉ាទ្រីសមានលំដាប់ $m\times n$ និង $B=\left[b_{ij}\right]$ ជាម៉ាទ្រីសមានលំដាប់ $n\times p$ នោះផលគុណម៉ាទ្រីស $A$ និង $B$ កំណត់ដោយ $A\cdot B$ មានលំដាប់ $m\times p$

$A\cdot B=\left[a_{ij}\right]\times\left[b_{ij}\right]\times\left[c_{ij}\right]$

លំដាប់ $m\times n$ $n\times p$ $=$ $m\times p$

ដែល $c_{ij}=a_{i1}b_{1j}+a_{i2}b_{2j}a_{i3}b_{3j}+\dots+a_{in}b_{nj}$ ។

**ជាទូទៅ** បើ $A$ ជាម៉ាទ្រីសលំដាប់ $m\times n$ និង $B$ ជាម៉ាទ្រីសលំដាប់ $n\times p$ នោះផលគុណ $AB$ ជាម៉ាទ្រីស $m\times p$ ដែលធាតុរបស់វាកំណត់ដោយ:

- ដើម្បីរកធាតុនៅក្នុងជួរដេកទី $i$ និងជួរឈរទី $j$ នៃ $AB$ យើងយកជួរដេកទី $i$ តែមួយគត់ចេញពីម៉ាទីស $A$ និងជួរទី $j$ តែមួយគត់ចេញពីម៉ាទ្រីស $B$ ។
- គុណធាតុដែលត្រូវគ្នាពីជួរដេក និងជួរឈរនេះហើយបូកលទ្ធផលដែលទទួលបាននោះគេសរសេរកំណត់ដោយ

$$A=\begin{bmatrix}a_{11} & a_{12}\\ a_{21} & a_{22}\end{bmatrix},\ B=\begin{bmatrix}b_{11} & b_{12}\\ b_{21} & b_{22}\end{bmatrix}\Rightarrow AB=\begin{bmatrix}a_{11} & a_{12}\\ a_{21} & a_{22}\end{bmatrix}\begin{bmatrix}b_{11} & b_{12}\\ b_{21} & b_{22}\end{bmatrix}$$

$$=\begin{bmatrix}a_{11}b_{11}+a_{12}b_{21} & a_{11}b_{12}+a_{12}b_{22}\\ a_{21}b_{11}+a_{22}b_{21} & a_{21}b_{12}+a_{22}b_{22}\end{bmatrix}$$

- **លក្ខណៈផលគុណម៉ាទ្រីស**

តាង $A, B$ និង $C$ ជាម៉ាទ្រីស និងតាង $c$ ជាស្កាលែ

$i)$ $A(BC)=(AB)C$ លក្ខណៈផ្តុំនៃផលគុណ

$ii)$ $AB\neq BA$ ជាផលគុណគ្មានលក្ខណៈត្រលប់

$iii)$ $A(B+C)=AB+AC$ លក្ខណៈបំបែកខាងឆ្វេងនៃវិធីគុណចំពោះវិធីបូកម៉ាទ្រីស

$iv)$ $(A+B)C=AC+BC$ លក្ខណៈបំបែកខាងស្តាំនៃវិធីគុណចំពោះវិធីបូកម៉ាទ្រីស

$v)\quad c(AB)=(cA)B=A(cB)$

$vi)\quad I_nA=AI_n=A$

$vii)\quad A(B-C)=AB-AC$ លក្ខណៈបំបែកខាងឆ្វេងនៃវិធីគុណចំពោះវិធីដកម៉ាទ្រីស

$viii)\quad (A-B)C=AC-BC$ លក្ខណៈបំបែកខាងស្តាំនៃវិធីគុណចំពោះវិធីបូកម៉ាទ្រីស

$ix)\quad (a+b)C=aC+bC$

$x)\quad (a-b)C=aC-bC$

$xi)\quad a(bC)=(ab)C$

## 3. ទម្រង់ម៉ាទ្រីសនៃប្រព័ន្ធសមីការលីនេអ៊ែរ (*Matrix Form of a Linear System*)

ប្រមាណវិធីគុណម៉ាទ្រីស គឺជាអនុវត្តមួយដ៏សំខាន់ចំពោះប្រព័ន្ធសមីការលីនេអ៊ែរ ។ ពិនិត្យប្រព័ន្ធសមីការមួយដែលមាន $m$ សមីការលីនេអ៊ែរ និងមាន $n$ អញ្ញាតខាងក្រោម:

$$\begin{cases} a_{11}x_1+a_{12}x_2+\dots+a_{1n}x_n &= b_1 \\ a_{21}x_1+a_{22}x_2+\dots+a_{2n}x_n &= b_2 \\ \vdots \qquad \vdots \qquad \vdots & \vdots \\ a_{m1}x_1+a_{m2}x_2+\dots+a_{mn}x_n &= b_m \end{cases}$$

ដោយម៉ាទ្រីសពីរស្មើគ្នា លុះត្រាតែធាតុដែលត្រូវគ្នាទាំងអស់របស់វាស្មើគ្នា នោះយើងអាចជំនួស $m$ សមីការទៅក្នុងប្រព័ន្ធសមីការនេះដោយសមីការម៉ាទ្រីសមួយ

$$\begin{bmatrix} a_{11}x_1+a_{12}x_2+\dots+a_{1n}x_n \\ a_{21}x_1+a_{22}x_2+\dots+a_{2n}x_n \\ \vdots \qquad \vdots \qquad \vdots \\ a_{m1}x_1+a_{m2}x_2+\dots+a_{mn}x_n \end{bmatrix}=\begin{bmatrix} b_1 \\ b_2 \\ \vdots \\ b_m \end{bmatrix}$$

ម៉ាទ្រីស $m\times 1$ នៅខាងឆ្វេងនៃសមីការម៉ាទ្រីសនេះអាចសរសេរជាផលគុណម៉ាទ្រីសកំណត់ដោយ:

$$\begin{bmatrix} a_{11} & a_{12}\dots a_{1n} \\ a_{21} & a_{22}\dots a_{2n} \\ \vdots & \vdots \quad \vdots \\ a_{m1} & a_{m2}\dots a_{mn} \end{bmatrix}\begin{bmatrix} x_1 \\ x_2 \\ \vdots \\ x_n \end{bmatrix}=\begin{bmatrix} b_1 \\ b_2 \\ \vdots \\ b_m \end{bmatrix}$$

តាងម៉ាទ្រីសទាំងបីនេះដោយអក្សរ $A$, $X$ និង $B$ រៀងគ្នានោះប្រព័ន្ធសមីការដើមដែលមាន $m$ សមីការលីនេអ៊ែរ និងមាន $n$ អញ្ញាតត្រូវជំនួសដោយសមីការម៉ាទ្រីសមួយគឺ $AX=B$ (1)

ម៉ាទ្រីស $A$ ក្នុងសមីការ $m$ ហៅថា **ម៉ាទ្រីសមេគុណ** (*Coeffficient Matrix*) ចំពោះប្រព័ន្ធសមីការលីនេអ៊ែរខាងលើ ។

ឧទាហរណ៍ គេមានប្រព័ន្ធសមីការខាងក្រោម ៖ $\begin{cases} x_1+x_2+x_3+x_4+x_5=3 \\ 2x_1+3x_2+3x_3+x_4-x_5=0 \\ -x_1+2x_2-5x_3+2x_4-x_5=1 \\ 3x_1-x_2+2x_3-3x_4-2x_5=-1 \end{cases}$

គេបាន $A=\begin{bmatrix} 1 & 1 & 1 & 1 & 1 \\ 2 & 3 & 3 & 1 & -1 \\ -1 & 2 & -5 & 2 & -1 \\ 3 & -1 & 2 & -3 & -2 \end{bmatrix}, X=\begin{bmatrix} x_1 \\ x_2 \\ x_3 \\ x_4 \\ x_5 \end{bmatrix}, b=\begin{bmatrix} 3 \\ 0 \\ 1 \\ -1 \end{bmatrix}$

គេអាចសរសេរជា $AX=B \Leftrightarrow \begin{bmatrix} 1 & 1 & 1 & 1 & 1 \\ 2 & 3 & 3 & 1 & -1 \\ -1 & 2 & -5 & 2 & -1 \\ 3 & -1 & 2 & -3 & -2 \end{bmatrix}\begin{bmatrix} x_1 \\ x_2 \\ x_3 \\ x_4 \\ x_5 \end{bmatrix}=\begin{bmatrix} 3 \\ 0 \\ 1 \\ -1 \end{bmatrix}$

## 4. ម៉ាទ្រីសត្រង់ស្ប៉ូ (*Transpose of a Matrix*)

**និយមន័យ** ម៉ាទ្រីស $A=\left[a_{ij}\right]$ ជាម៉ាទ្រីសលំដាប់ $m\times n$ នោះត្រង់ស្ប៉ូនៃ $A$ កំណត់ដោយ $A^T$ ដែល $A^T=\left[a_{ji}\right]$ ។

ឧទាហរណ៍ ម៉ាទ្រីស $A=\begin{bmatrix} a_{11} & b_{12} & c_{13} \\ a_{21} & b_{22} & c_{23} \\ a_{31} & b_{32} & c_{33} \end{bmatrix} \Rightarrow$ ម៉ាទ្រីសត្រង់ស្ប៉ូនៃ $A$ គឺ $A^T=\begin{bmatrix} a_{11} & a_{21} & a_{31} \\ b_{12} & b_{22} & b_{32} \\ c_{13} & c_{23} & c_{33} \end{bmatrix}$

- លក្ខណៈម៉ាទ្រីសត្រង់ស្ប៉ូ
  - $i)$ $(A^T)^T=A$
  - $ii)$ $(A+B)^T=A^T+B^T$
  - $iii)$ $(A-B)^T=A^T-B^T$
  - $iv)$ $(AB)^T=A^TB^T$
  - $v)$ $(\lambda A)^T=\lambda A^T$ ដែល $\lambda$ ជាស្កាលែ

## 5. ចំរាស់នៃម៉ាទ្រីសការេ ( *Inverse of Square Matrix* )

**និយមន័យ** បើ $A$ ជាម៉ាទ្រីសការេមួយហើយបើមានម៉ាទ្រីស $A^{-1}$ ដែល $AA^{-1}=A^{-1}A=I$ នោះគេបានម៉ាទ្រីស $A^{-1}$ ជាម៉ាទ្រីសច្រាសនៃ $A$ ។

**ជាទូទៅ** ➢ បើម៉ាទ្រីស $A=\begin{bmatrix} a & b \\ c & d \end{bmatrix}$ នោះគេបាន **ចំរាស**នៃម៉ាទ្រីស $A$ កំណត់ដោយ $A^{-1}$

$$A^{-1}=\frac{1}{ad-bc}\begin{bmatrix} d & -b \\ -c & a \end{bmatrix}$$ បើ $ad-bc\neq 0$ ។

➢ ករណីបើ $ad-bc=0$ ឬមានន័យថា ដេទែមីណង់នៃ $A$ ស្មើសូន្យ នោះម៉ាទ្រីស $A$ គ្មានចំរាសទេ ។

➢ បើ $A^{-1}$ ជាម៉ាទ្រីសច្រាសនៃម៉ាទ្រីស $A$ នោះគេបាន $AA^{-1}=A^{-1}A=I$

ចំពោះម៉ាទ្រីសលំដាប់បីឡើងទៅគឺ $A^{-1}=\frac{1}{\det(A)}adj(A)$ , $adj=adjoint$

**និយមន័យ** បើ $A$ ជាម៉ាទ្រីស $n\times n$ និង $c_{ij}=(-1)^{i+j}\cdot M_{ij}$ ជា Cofactor នៃ $a_{ij}$ នោះ

ម៉ាទ្រីស $\begin{bmatrix} c_{11} & c_{12}\cdots c_{1n} \\ c_{21} & c_{22}\cdots c_{2n} \\ \vdots & \vdots \quad \vdots \\ c_{n1} & c_{n2}\cdots c_{nn} \end{bmatrix}$ ហៅថាម៉ាទ្រីសនៃ Cofactor នៃ $A$ ។ ម៉ាទ្រីសត្រង់ស្ប៉ូ នៃម៉ាទ្រីសនេះ ហៅថា adjoint នៃ $A$ ដែលគេតាងដោយ $adj(A)$ ។

**ឧទាហរណ៍** គេឲ្យម៉ាទ្រីស $A=\begin{bmatrix} 3 & 2 & -1 \\ 1 & 6 & 3 \\ 2 & -4 & 0 \end{bmatrix}$ នោះម៉ាទ្រីស Cofactor នៃ $A$ កំណត់ដោយ

$$c_{ij}=(-1)^{i+j}M_{ij} \Rightarrow c_{11}=(-1)^{1+1}\begin{vmatrix} 6 & 3 \\ -4 & 0 \end{vmatrix}=12 \quad , c_{12}=(-1)^{1+2}\begin{vmatrix} 1 & 3 \\ 2 & 0 \end{vmatrix}=6$$

$$c_{13}=(-1)^{1+3}\begin{vmatrix} 1 & 6 \\ 2 & -4 \end{vmatrix}=-16 \ , c_{21}=(-1)^{2+1}\begin{vmatrix} 2 & -1 \\ -4 & 0 \end{vmatrix}=-4$$

$$c_{22}=(-1)^{2+2}\begin{vmatrix} 3 & -1 \\ 2 & 0 \end{vmatrix}=2 \quad , c_{23}=(-1)^{2+3}\begin{vmatrix} 3 & 2 \\ 2 & -4 \end{vmatrix}=16$$

$$c_{31}=(-1)^{3+1}\begin{vmatrix} 2 & -1 \\ 6 & 3 \end{vmatrix}=12 \quad , c_{32}=(-1)^{3+2}\begin{vmatrix} 3 & -1 \\ 1 & 3 \end{vmatrix}=-10$$

$$c_{33}=(-1)^{3+3}\begin{vmatrix} 3 & 2 \\ 1 & 6 \end{vmatrix}=16$$

គេបានម៉ាទ្រីស Cofactor នៃ $A$ គឺ $\begin{bmatrix} 12 & 6 & -16 \\ -4 & 2 & 16 \\ 12 & -10 & 16 \end{bmatrix}$ ។

ហើយ $adj(A)=\begin{bmatrix}12 & 6 & -16\\ -4 & 2 & 16\\ 12 & -10 & 16\end{bmatrix}^T=\begin{bmatrix}12 & -4 & 12\\ 6 & 2 & -10\\ -16 & 16 & 16\end{bmatrix}$ ។

- ដើម្បីរកម៉ាទ្រីសច្រាសនៃម៉ាទ្រីសមានចំរាស់ $A$ យើងត្រូវសម្រួល $A$ ទៅជាម៉ាទ្រីសឯកតាតាមប្រមាណវិធីជួរដេក ហើយអនុវត្តន៍ប្រមាណវិធីនេះលើ $I$ ដើម្បីបាន $A^{-1}$ ។ ដើម្បីបំពេញលក្ខណៈនេះ យើងនឹងភ្ជាប់ម៉ាទ្រីសឯកតាទៅផ្នែកខាងស្តាំនៃ $A$ រួចបង្កើតម៉ាទ្រីសរាង: $[A|I]$ បន្ទាប់មកយើងនឹងអនុវត្តប្រមាណវិធីជួរដេកចំពោះម៉ាទ្រីសនេះរហូតដល់អង្គខាងឆ្វេងត្រូវសម្រួលទៅជា $I$ ។ ប្រមាណវិធីនេះនឹងធ្វើឲ្យអង្គខាងស្តាំផ្លាស់ជា $A^{-1}$ ។

ដូច្នេះ ម៉ាទ្រីសចុងក្រោយនឹងមានទម្រង់: $\left[I|A^{-1}\right]$ មានន័យថា $\left[A|I\right]\to\left[I|A^{-1}\right]$ ។

ឧទាហរណ៍ $\left[\begin{array}{ccc|ccc}1 & 2 & 3 & 1 & 0 & 0\\ 2 & 5 & 3 & 0 & 1 & 0\\ 1 & 0 & 8 & 0 & 0 & 1\end{array}\right]\Rightarrow\left[\begin{array}{ccc|ccc}1 & 0 & 0 & -40 & 16 & 9\\ 0 & 1 & 0 & 13 & -5 & -3\\ 0 & 0 & 1 & 5 & -2 & -1\end{array}\right]$

ដូច្នេះ $A^{-1}=\begin{bmatrix}-40 & 16 & 9\\ 13 & -5 & -3\\ 5 & -2 & -1\end{bmatrix}$ ។

**ទ្រឹស្តីបទ** បើ $B$ និង $C$ ជាម៉ាទ្រីសច្រាសនៃម៉ាទ្រីស $A$ នោះ $B=C$ ។

<u>សម្រាយបញ្ជាក់</u>

ដោយ $B$ ជាម៉ាទ្រីសច្រាសនៃ $A$ នោះ $BA=I$

គេបាន $(BA)C=IC=C$

$(BA)C=B(AC)=BI=B$ ($C$ ជាម៉ាទ្រីសច្រាសនៃ $A$)

ដូច្នេះ $B=C$ ។

**ទ្រឹស្តីបទ** បើ $B$ និង $C$ ជាម៉ាទ្រីសមានចំរាសដែលមានលំដាប់ដូចគ្នា នោះគេបាន ៖

$a)$ ម៉ាទ្រីស $AB$ មានចំរាស

$b)$ $(AB)^{-1}=B^{-1}A^{-1}$

<u>សម្រាយបញ្ជាក់</u>

យើងគ្រាន់តែបង្ហាញថា: $(AB)(B^{-1}A^{-1})=(B^{-1}A^{-1})(AB)=I$ ។ តាមលក្ខណៈប្រមាណវិធីលើម៉ាទ្រីស គេបាន: $(AB)(B^{-1}A^{-1})=A(BB^{-1})A^{-1}=AIA^{-1}=AA^{-1}=I$

ហើយ $(B^{-1}A^{-1})(AB)=B^{-1}(A^{-1}A)B=B^{-1}IB=B^{-1}B=I$

ដូច្នេះ $(AB)(B^{-1}A^{-1}) = (B^{-1}A^{-1})(AB) = I$ ។

- យើងអាចទាញបញ្ជាក់នូវរូបមន្តដូចខាងក្រោម
  ផលគុណនៃម៉ាទ្រីសច្រាស ជាម៉ាទ្រីសមានចម្រាសជានិច្ច ហើយម៉ាទ្រីសច្រាសនៃម៉ាទ្រីសផលគុណជាផលគុណនៃម៉ាទ្រីសច្រាសតាមលំដាប់ច្រាស ។
- លក្ខណៈនៃម៉ាទ្រីសច្រាស
  1) $AB = BA = I_n$
  2) $AA^{-1} = I_n$ , $A^{-1}A = I_n$
  3) $(A^{-1})^{-1} = A$
  4) $AB = I_n$ នោះ $B = A^{-1}$
  5) $(AB)^{-1} = B^{-1}A^{-1}$
  6) $A^{-1}(AB) = B$
  7) បើ $B$ និង $C$ ជាម៉ាទ្រីសច្រាសនៃ $A$ នោះ $B = C$

## 6. ម៉ាទ្រីសស្វ័យគុណ (*Power of a Matrix*)

**និយមន័យ**

- បើ $A$ ជាម៉ាទ្រីសមានការេ នោះគេកំណត់ស្វ័យគុណចំនួនគត់វិជ្ជមាននៃ $A$ ដោយ $A^0 = 1$ និង $A^n = \underbrace{AA.......A}_{n\ time}, (n > 0)$ ។
- បើ $A$ មានចម្រាសកំណត់ស្វ័យគុណចំនួនគត់អវិជ្ជមាននៃ $A$ ដោយ $A^{-n} = (A^{-1})^n = \underbrace{A^{-1}A^{-1}...A^{-1}A^{-1}}_{n\ time}$ ។

**លក្ខណៈ:** បើម៉ាទ្រីស $A$ មានចម្រាស នោះគេបាន

$a)$ $A^{-1}$ មានចម្រាស ហើយ $(A^{-1})^{-1} = A$

$b)$ $A^n$ មានចម្រាស ហើយ $(A^n)^{-1} = (A^{-1})^n$ , $n = 0, 1, 2, ...$

$c)$ ចំពោះស្កាលែ $k = 0$ , $kA$ មានចម្រាស ហើយ $(kA)^{-1} = \frac{1}{k}A^{-1}$

## 7. លក្ខណៈនៃម៉ាទ្រីសត្រង់ស្ប៉ូ (*Property of Transpose's Matrix*)

**ទ្រឹស្តីបទ** បើលំដាប់នៃម៉ាទ្រីសជាលំដាប់ដែលអាចធ្វើប្រមាណវិធីបាន នោះលក្ខណៈខាងក្រោមនេះផ្ទៀងផ្ទាត់ ៖

$a)\quad (A^T)^T = A$

$b)\quad (A+B)^T = A^T + B^T$

$c)\quad (kA)^T = kA^T$ ដែល $k$ ជាស្កាលែ

$d)\quad (AB)^T = B^T A^T$

## 8. ម៉ាទ្រីសស៊ីមេទ្រី ( *Symmetric Matrix* )

- **ម៉ាទ្រីសស៊ីមេទ្រី** *ម៉ាទ្រីសស៊ីមេទ្រីគឺជាម៉ាទ្រីសការេដែលមានធាតុស៊ីមេទ្រីធៀបនឹងអង្កត់ទ្រូងមេស្មើគ្នា ។ យើងប្តូរពីជួរដេកទៅជាជួរឈរនៃម៉ាទ្រីស $A$ នោះគេបាន:*

$$A = \begin{pmatrix} a_{11} & a_{12} & a_{13} \\ a_{21} & a_{22} & a_{23} \\ a_{31} & a_{32} & a_{33} \end{pmatrix} \Rightarrow A^T = \begin{pmatrix} a_{11} & a_{12} & a_{31} \\ a_{12} & a_{22} & a_{32} \\ a_{13} & a_{23} & a_{33} \end{pmatrix}$$

ចំពោះម៉ាទ្រីសស៊ីមេទ្រីគេបាន $A = A^T$ ។

- **ម៉ាទ្រីសច្រាសស៊ីមេទ្រី** *ម៉ាទ្រីស $A$ ជាម៉ាទ្រីសច្រាសស៊ីមេទ្រីកាលណា* $A^T = -A$

# ដេទែមីណង់ (*Determinant*)

## 1. អនុគមន៍ដេទែមីណង់

យើងនឹងសិក្សានូវអនុគមន៍ទាំងឡាយណាដែលមានទម្រង់ដូចគ្នានឹងអនុគមន៍ $f(x)=x^2$ និង $f(x)=\sin x$ ដែលកំណត់បាននូវចំនួនពិត $f(x)$ មួយចំពោះតម្លៃនៃអថេរពិត $x$ ។ ដោយហេតុថា $x$ និង $f(x)$ មានតម្លៃជាចំនួនពិត ដូច្នេះ អនុគមន៍បែបនេះគេហៅថា **អនុគមន៍យក តម្លៃពិតនៃអថេរពិតមួយ** ។ **អនុគមន៍ដែទែមីណង់** ដែលជា**អនុគមន៍យកតម្លៃពិតនៃអថេរមានរាងជាម៉ាទ្រីសមួយ** មានន័យថា វានឹងកំណត់បាននូវតម្លៃពិតនៃ $f(x)$ តាមតម្លៃនៃម៉ាទ្រីស $X$ ។ ការសិក្សាអនុគមន៍ដេទែមីណាងនេះ និងផ្តល់សារៈសំខាន់សម្រាប់អនុវត្តចំពោះទ្រឹស្តីបទនៃប្រព័ន្ធសមីការលីនេ-អ៊ែរ ហើយនឹងនាំឲ្យយើងអាចទាញបាននូវរូបមន្តចម្រាសនៃម៉ាទ្រីសដែលអាចធ្វើចម្រាសបាន ។

**និយមន័យ** $A$ ជាម៉ាទ្រីសការេមួយ ។ អនុគមន៍ដេទែមីណង់តាងដោយ $\det$ ហើយយើងអាចតាង $\det(A)$ គឺជាផលបូកនៃគ្រប់ផលគុណដំបូងដែលមានសញ្ញាទាំងអស់នៃម៉ាទ្រីស $A$ ។ លទ្ធផលនៃ $\det(A)$ នេះហៅថា **ដេទែមីណង់នៃ** $A$ ។

## 2. ដេទែមីណង់លំដាប់ 2

បើគេមានម៉ាទ្រីសលំដាប់ 2 ដែល $A=\begin{bmatrix} a & b \\ c & d \end{bmatrix}$ ។ កន្សោម $ad-cb$ ហៅថា**ដេទែមីណង់លំដាប់** 2 នៃម៉ាទ្រីស $A$ ។ គេកំណត់សរសេរដោយៈ $\det(A)$ ឬ $|A|$ ឬ $\begin{vmatrix} a & b \\ c & d \end{vmatrix}$ ។

ដូច្នេះ $\det A=|A|=\begin{vmatrix} a & b \\ c & d \end{vmatrix}=ad-bc$

## 3. ដេទែមីណង់លំដាប់3

### 3.1 គណនាដេទែមីណង់លំដាប់ 3 តាមក្បួនរបស់សារុស

គេមានម៉ាទ្រីស $A$ លំដាប់3 ដែល $A=\begin{bmatrix} a_1 & b_1 & c_1 \\ a_2 & b_2 & c_2 \\ a_3 & b_3 & c_3 \end{bmatrix}$ ។ ដេទែមីណង់នៃ $A$ កំណត់ដោយ

$\det(A)=$  $= a_1b_2c_3+b_1c_2a_3+c_1a_2b_3-a_3b_2c_1-b_3c_2a_1-c_3a_2b_1$ ។

### 3.2 គណនាដេទែមីណង់លំដាប់ 3 តាមមីន័រ

គេមាន $\begin{vmatrix} a_1 & b_1 & c_1 \\ a_2 & b_2 & c_2 \\ a_3 & b_3 & c_3 \end{vmatrix} = a_1b_2c_3 + b_1c_2a_3 + c_1a_2b_3 - a_3b_2c_1 - b_3c_2a_1 - c_3a_2b_1$

គេអាចសរសេរ $\begin{vmatrix} a_1 & b_1 & c_1 \\ a_2 & b_2 & c_2 \\ a_3 & b_3 & c_3 \end{vmatrix} = (a_1b_2c_3 - a_1c_2b_3) - (b_1a_2c_3 - b_1c_2a_3) + (c_1a_2b_3 - c_1b_2a_3)$

$= a_1(b_2c_3 - c_2b_3) - b_1(a_2c_3 - c_2a_3) + c_1(a_2b_3 - b_2a_3)$

ដូច្នេះ $\begin{vmatrix} a_1 & b_1 & c_1 \\ a_2 & b_2 & c_2 \\ a_3 & b_3 & c_3 \end{vmatrix} = a_1\begin{vmatrix} b_2 & c_2 \\ b_3 & c_3 \end{vmatrix} - b_1\begin{vmatrix} a_2 & c_2 \\ a_3 & c_3 \end{vmatrix} + c_1\begin{vmatrix} a_2 & b_2 \\ a_3 & b_3 \end{vmatrix}$ ។

គេហៅថាពន្លាតមីន័រតាមជួរដេកទី 1 ព្រោះ $a_1$ , $b_1$ , $c_1$ ជាធាតុស្ថិតនៅជួរដេកទី 1 $\begin{vmatrix} b_2 & c_2 \\ b_3 & c_3 \end{vmatrix}$ មីន័រនៃធាតុ $a_1$ , $\begin{vmatrix} a_2 & c_2 \\ a_3 & c_3 \end{vmatrix}$ មីន័រនៃធាតុ $b_1$ , $\begin{vmatrix} a_2 & b_2 \\ a_3 & b_3 \end{vmatrix}$ មីន័រនៃធាតុ $c_1$ ។

- មីន័រនៃធាតុ $a_1$ បានពីការលុបជួរឈរ និងជួរដេកដែលមានធាតុ $a_1$ $\begin{vmatrix} a_1 & b_1 & c_1 \\ a_2 & b_2 & c_2 \\ a_3 & b_3 & c_3 \end{vmatrix}$
- មីន័រនៃធាតុ $b_1$ បានពីការលុបជួរឈរ និងជួរដេកដែលមានធាតុ $b_1$ $\begin{vmatrix} a_1 & b_1 & c_1 \\ a_2 & b_2 & c_2 \\ a_3 & b_3 & c_3 \end{vmatrix}$
- មីន័រនៃធាតុ $c_1$ បានពីការលុបជួរឈរ និងជួរដេកដែលមានធាតុ $c_1$ $\begin{vmatrix} a_1 & b_1 & c_1 \\ a_2 & b_2 & c_2 \\ a_3 & b_3 & c_3 \end{vmatrix}$

**ចំណាំ** ក្នុងការគណនាដេទែមីណង់លំដាប់តាមមីន័រ គេអាចពន្លាតតាមជួរណាមួយក៏បានប៉ុន្តែសញ្ញានៃតម្លៃនីមួយៗអាស្រ័យនឹងលំដាប់ទីដែលធាតុស្ថិតនៅដូចជា ៖ $c_1$ មានសញ្ញា $+$ ព្រោះ $a_1$ ជាធាតុនៅជួរដេកទី 1 និងជួរឈរទី 1 , $1+1=2$ គូ , $b_1$ មានសញ្ញា $-$ ព្រោះ $b_1$ ជាធាតុនៅជួរដេកទី 1 និងជួរឈរទី 2 , $1+2=3$ សេស ។

$$\begin{bmatrix} + & - & + \\ - & + & - \\ + & - & + \end{bmatrix}$$

## 4. ដោះស្រាយប្រព័ន្ធសមីការលីនេអ៊ែរ

### 4.1 ទម្រង់ម៉ាទ្រីសនៃប្រព័ន្ធសមីការលីនេអ៊ែរ

ប្រមាណវិធីគុណម៉ាទ្រីស គឺជាអនុវត្តមួយដ៏សំខាន់ចំពោះប្រព័ន្ធសមីការលីនេអ៊ែរ ។ ពិនិត្យប្រព័ន្ធសមីការលីនេអ៊ែរដែលមាន $m$ សមីការលីនេអ៊ែរនិងមាន $n$

អញ្ញាតខាងដែលមានរាង $\begin{cases} a_{11}x_1 & a_{12}x_2\dots & a_{1n}x_n = b_1 \\ a_{21}x_1 & a_{22}x_2\dots & a_{2n}x_n = b_2 \\ \vdots & \vdots & \vdots \\ a_{m1}x_1 & a_{m2}x_2\dots & a_{mn}x_n = b_m \end{cases}$

ដោយម៉ាទ្រីសពីរស្មើគ្នាលុះត្រាតែ ធាតុដែលត្រូវគ្នាទាំងអស់របស់វាស្មើគ្នា នោះយើងអាចជំនួស $m$ សមីការទៅក្នុងប្រព័ន្ធសមីការនេះដោយសមីការម៉ាទ្រីសមួយ:

$$\begin{bmatrix} a_{11}x_1 + a_{12}x_2\dots + a_{1n}x_n \\ a_{21}x_1 + a_{22}x_2\dots + a_{2n}x_n \\ \vdots \quad \vdots \quad \vdots \\ a_{m1}x_1 + a_{m2}x_2\dots + a_{mn}x_n \end{bmatrix} = \begin{bmatrix} b_1 \\ b_2 \\ \vdots \\ b_n \end{bmatrix}$$

ម៉ាទ្រីស $m\times 1$ នៅអង្គខាងឆ្វេងនៃសមីការម៉ាទ្រីសនេះអាចសរសេរជាផលគុណម៉ាទ្រីសកំណត់ដោយ

$$\begin{bmatrix} a_{11} & a_{12}\dots a_{1n} \\ a_{21} & a_{22}\dots a_{2n} \\ \vdots & \vdots \quad \vdots \\ a_{m1} & a_{m2}\dots a_{mn} \end{bmatrix}\begin{bmatrix} x_1 \\ x_2 \\ \vdots \\ x_n \end{bmatrix} = \begin{bmatrix} b_1 \\ b_2 \\ \vdots \\ b_n \end{bmatrix}$$

បើយើងតាងម៉ាទ្រីសទាំងបីនេះដោយអក្សរ $A$, $X$ និង $B$ រៀងគ្នានោះប្រព័ន្ធសមីការដើមដែលមាន $m$ សមីការលីនេអ៊ែរនិងមាន $n$ អញ្ញាតត្រូវជំនួសដោយសមីការមួយគឺ: $AX = B$ ។

### 4.2 ដោះស្រាយប្រព័ន្ធសមីការតាមក្រាម៉ែរ (*Cramer* Rule)

បើ $AX = B$ ជាប្រព័ន្ធសមីការលីនេអ៊ែរដែលមាន $n$ អញ្ញាត ដែល $\det(A) = 0$ នោះប្រព័ន្ធសមីការមានចម្លើយតែមួយគត់គឺ៖

$$x_1 = \frac{\det(A_1)}{\det(A)},\ x_2 = \frac{\det(A_2)}{\det(A)},\ \dots\dots, x_2 = \frac{\det(A_n)}{\det(A)}$$

ដែល $A_j$ ជាម៉ាទ្រីសដែលបានមកពីការជំនួសធាតុទៅក្នុងជួរទី $j$ នៃម៉ាទ្រីស $A$ ដោយម៉ាទ្រីស $B$ ។

ដែលម៉ាទ្រីស $B$ កំណត់ដោយ $B = \begin{bmatrix} b_1 \\ b_2 \\ \vdots \\ b_n \end{bmatrix}$

**ឧទាហរណ៍** ដោះស្រាយប្រព័ន្ធសមីការតាមវិធីក្រាម៉ែរ $\begin{cases} 3x + 2y - 2z = 2 \\ 2x - 3y - z = -2 \\ x + y - z = 0 \end{cases}$

គេបាន $D = \begin{vmatrix} 3 & 2 & -2 \\ 2 & -3 & -1 \\ 1 & 1 & -1 \end{vmatrix} = 4$ , $D_x = \begin{vmatrix} 2 & 2 & -2 \\ -2 & -3 & -1 \\ 0 & 1 & -1 \end{vmatrix} = 8$

$$D_y = \begin{vmatrix} 3 & 2 & -2 \\ 2 & -2 & -1 \\ 1 & 0 & -1 \end{vmatrix} = 4 \quad , \quad D_z = \begin{vmatrix} 3 & 2 & 2 \\ 2 & -3 & -2 \\ 1 & 1 & 0 \end{vmatrix} = 12$$

គេបាន $x = \dfrac{D_x}{D} = 2$ , $y = \dfrac{D_y}{D} = 1$ , $z = \dfrac{D_z}{D} = 3$

ដូចនេះ | ចម្លើយនៃប្រព័ន្ធសមីការគឺ $x = 2$ , $y = 1$ , $z = 3$ ។ |

**4.3** **ដោះស្រាយប្រព័ន្ធសមីការតាម $(Guass - Jordan)$**

ដោះស្រាយប្រព័ន្ធសមីការខាងក្រោមតាមវិធី $(Guass - Jordan)$

$$\begin{cases} 3x + 2y - 2z = 2 \\ 2x - 3y - z = -2 \\ x + y - z = 0 \end{cases}$$

គេបាន

$$\left[\begin{array}{ccc|c} 3 & 2 & -2 & 2 \\ 2 & -3 & -1 & -2 \\ 1 & 1 & -1 & 0 \end{array}\right] \quad R_1 \leftrightarrow R_3$$

$$\left[\begin{array}{ccc|c} 1 & 1 & -1 & 0 \\ 2 & -3 & -1 & -2 \\ 3 & 2 & -2 & 2 \end{array}\right] \quad \begin{array}{l} R_1 \to R_2 - 2R_1 \\ R_3 \to R_3 - 3R_1 \end{array}$$

$$\left[\begin{array}{ccc|c} 1 & 1 & -1 & 0 \\ 0 & -5 & 1 & -2 \\ 0 & -1 & 1 & 2 \end{array}\right] \quad R_2 \to -\frac{1}{5} R_2$$

$$\left[\begin{array}{ccc|c} 1 & 1 & -1 & 0 \\ 0 & 1 & -1/5 & 2/5 \\ 0 & -1 & 1 & 2 \end{array}\right] \quad \begin{array}{l} R_1 \to R_1 - R_2 \\ R_3 \to R_3 + R_2 \end{array}$$

$$\left[\begin{array}{ccc|c} 1 & 0 & -4/5 & -2/5 \\ 0 & 1 & -1/5 & 2/5 \\ 0 & 0 & 4/5 & 12/5 \end{array}\right] \quad R_3 \to \frac{5}{4} R_3$$

$$\left[\begin{array}{ccc|c} 1 & 0 & -4/5 & -2/5 \\ 0 & 1 & -1/5 & 2/5 \\ 0 & 0 & 1 & 3 \end{array}\right] \quad \begin{array}{l} R_1 \to R_1 + \frac{4}{5} R_3 \\ R_2 \to R_2 + \frac{1}{5} R_3 \end{array}$$

$$\left[\begin{array}{ccc|c}1&0&0&2\\0&1&0&1\\0&0&1&3\end{array}\right]$$

ដូច្នេះ ប្រព័ន្ធសមីការមានចម្លើយ: $x=2\,,\,y=1,z=3$ ។

**4.4 ដោះស្រាយប្រព័ន្ធសមីការតាមចម្រាសនៃម៉ាទ្រីស**

បើ $A$ ជាម៉ាទ្រីសដែលមានចម្រាស នោះម៉ាទ្រីសច្រាសនៃ $A$ តាងដោយ $A^{-1}$ កំណត់ដោយ

$$A^{-1}=\frac{1}{\det(A)}adj(A) \quad ។$$

**ឧទាហរណ៍** ដោះស្រាយប្រព័ន្ធសមីការតាមវិធីម៉ាទ្រីសច្រាស (Inverse Matrix)

$$\begin{cases}3x+2y-2z=2\\2x-3y-z=-2\\x+y-z=0\end{cases}$$

តាង $A=\begin{bmatrix}3&2&-2\\2&-3&-1\\1&1&-1\end{bmatrix}\,,\;B=\begin{bmatrix}2\\-2\\0\end{bmatrix}\,,\;X=\begin{bmatrix}x\\y\\z\end{bmatrix}$

ប្រព័ន្ធសមីការអាចសរសេរបានជារាង $AX=B\Rightarrow X=A^{-1}B$

តាមរូបមន្ត $A^{-1}=\dfrac{1}{\det(A)}adj(A)$ ដោយ $\det(A)=4$

- តាម cofactor

$$c_{11}=\begin{vmatrix}-3&-1\\1&-1\end{vmatrix}=4\,,\quad c_{12}=-\begin{vmatrix}2&-1\\1&-1\end{vmatrix}=1\,,\quad c_{13}=\begin{vmatrix}2&-3\\1&1\end{vmatrix}=5$$

$$c_{21}=-\begin{vmatrix}2&-2\\1&-1\end{vmatrix}=0\,,\quad c_{22}=\begin{vmatrix}3&-2\\1&-1\end{vmatrix}=-1\,,\quad c_{23}=-\begin{vmatrix}3&-2\\1&-1\end{vmatrix}=-1$$

$$c_{31}=\begin{vmatrix}2&-2\\-3&-1\end{vmatrix}=-8\,,\quad c_{32}=-\begin{vmatrix}3&-2\\2&-1\end{vmatrix}=-1\,,\quad c_{33}=\begin{vmatrix}3&2\\2&-3\end{vmatrix}=-13$$

$$\Rightarrow cof\,(A)=\begin{bmatrix}4&1&5\\0&-1&-1\\-8&-1&-13\end{bmatrix}$$

$$\Rightarrow adj(A)=\left[(cof\,)\right]^T=\begin{bmatrix}4&1&5\\0&-1&-1\\-8&-1&-13\end{bmatrix}^T=\begin{bmatrix}4&0&-8\\1&-1&-1\\5&-1&0\end{bmatrix}$$

គេបាន $X = A^{-1}B = \frac{1}{4}\begin{bmatrix} 4 & 1 & -8 \\ 1 & -1 & -1 \\ 5 & -1 & 0 \end{bmatrix}\begin{bmatrix} 2 \\ -2 \\ 0 \end{bmatrix} \Rightarrow X = \begin{bmatrix} 2 \\ 1 \\ 3 \end{bmatrix} = \begin{bmatrix} x \\ y \\ z \end{bmatrix}$

ដូច្នេះ ប្រព័ន្ធសមីការមានគូរចម្លើយមានចំលើយ $x = 2$ , $y = 1, z = 3$ ។

# ផ្នែកលំហាត់

១. គេឲ្យម៉ាទ្រីស

$$A=\begin{bmatrix}3&0\\-1&2\\1&1\end{bmatrix};\ B=\begin{bmatrix}4&-1\\0&2\end{bmatrix};\ C=\begin{bmatrix}1&4&2\\3&1&5\end{bmatrix};\ D=\begin{bmatrix}1&5&2\\-1&0&1\\3&2&4\end{bmatrix};\ E=\begin{bmatrix}6&1&3\\-1&1&2\\4&1&3\end{bmatrix}$$

គណនាកន្សោមខាងក្រោមបើអាចធ្វើបាន:

ក. $D+E$ ខ. $D-E$ គ. $5A$ ឃ. $-7C$ ង. $3B-C$

ច. $4E-2D$ ឆ. $-3(D+2E)$ ជ. $A-A$។

២. ដោះស្រាយប្រព័ន្ធសមីការលីនេអ៊ែរខាងក្រោមតាមរូបមន្តក្រាមែរ ( *Gramer's Rule*)

ក. $\begin{cases}3x-y=1\\x+2y=0\end{cases}$ ខ. $\begin{cases}4x-3y=2\\3x+4y=5\end{cases}$

គ. $\begin{cases}x-17y+18z=2\\19x-18y-z=0\\x+3y-2z=2\end{cases}$ ឃ. $\begin{cases}x+y+z=4\\x+2y+z=5\\x-y=-1\end{cases}$

ង. $\begin{cases}x+3y+2z=2\\x+4y+3z=3\\2x+7y+6z=8\end{cases}$ ច. $\begin{cases}2x+6y-4z=1\\x+3y-2z=4\\2x+y-3z=-7\end{cases}$

៣. ដោះស្រាយប្រព័ន្ធសមីការខាងក្រោមតាមរូបមន្ត *Guass – Jordan*

ក. $\begin{cases}2x-3y=-5\\3x+2y=12\end{cases}$ ខ. $\begin{cases}x-2y-3z=-1\\2x+y+z=6\\x+3y-2z=13\end{cases}$

គ. $\begin{cases}x-2y+3z=1\\x-y-7z=-4\\2x+4y+9z=-9\end{cases}$ ឃ. $\begin{cases}x+y+z=1\\x+2y-2z=0\\2x+3y-z=5\end{cases}$

ង. $\begin{cases}2x+y+z=0\\x-2y-2z=0\\x+y+z=0\end{cases}$ ច. $\begin{cases}a+2b-c-3d=2\\3a+b-2c-d=6\\a+b+3c-2d=-3\\-2a-2b+3c+d=-9\end{cases}$

ឆ. $\begin{cases}2\sin\alpha-\cos\beta+3\tan\gamma=3\\4\sin\alpha+2\cos\beta-2\tan\gamma=2\\6\sin\alpha-3\cos\beta+\tan\gamma=9\end{cases}$ ដែល $\begin{cases}0\le\alpha\le2\pi\\0\le\beta\le2\pi\\0\le\gamma\le2\pi\end{cases}$

ជ. $\begin{cases}x^2+y^2+z^2=6\\x^2-y^2+2z^2=2\\2x^2+y^2-z^2=3\end{cases}$

៤. កំណត់តម្លៃ $a$ ដើម្បីឲ្យប្រព័ន្ធសមីការគ្មានចម្លើយ, មានចម្លើយតែមួយគត់ និងមានចម្លើយរាប់មិនអស់

$$\begin{cases} x+2y-3z=4 \\ 3x-y+5z=2 \\ 4x+y+(a^2-14)z=a+2 \end{cases}$$

៥. រកម៉ាទ្រីស $A$ , $X$ និង $B$ ដែលសរសេរប្រព័ន្ធសមីការលីនេអ៊ែរខាងក្រោមជាសមីការម៉ាទ្រីស $AX=B$

ក. $\begin{cases} 2x_1-3x_2+5x_3=7 \\ 9x_1-x_2+x_3=-1 \\ x_1+5x_2+4x_3=0 \end{cases}$ ខ. $\begin{cases} 4x_1 \quad -3x_3+x_4=1 \\ 5x_1+x_2 \quad -8x_4=3 \\ 2x_1-5x_2+9x_3-x_4=0 \\ 3x_2-x_3+7x_4=2 \end{cases}$

៦ សរសេរសមីការម៉ាទ្រីស ជាប្រព័ន្ធសមីការលីនេអ៊ែរក្នុងករណីនីមួយៗខាងក្រោម:

ក. $\begin{bmatrix} 3 & -1 & 2 \\ 4 & 3 & 7 \\ -2 & 1 & 5 \end{bmatrix}\begin{bmatrix} x_1 \\ x_2 \\ x_3 \end{bmatrix}=\begin{bmatrix} 2 \\ -1 \\ 4 \end{bmatrix}$ ខ. $\begin{bmatrix} 3 & -2 & 0 & 1 \\ 5 & 0 & 2 & -2 \\ 3 & 1 & 4 & 7 \\ -2 & 5 & 1 & 6 \end{bmatrix}\begin{bmatrix} w \\ x \\ y \\ z \end{bmatrix}=\begin{bmatrix} 0 \\ 0 \\ 0 \\ 0 \end{bmatrix}$

៧. គេឲ្យម៉ាទ្រីស

$$A=\begin{bmatrix} a_{11} & a_{12} & \cdots & a_{1n} \\ a_{21} & a_{22} & \cdots & a_{2n} \\ \vdots & \vdots & & \vdots \\ a_{m1} & a_{m2} & \cdots & a_{mn} \end{bmatrix} ; D=\begin{bmatrix} d_1 & 0 & \cdots & 0 \\ 0 & d_2 & \cdots & 0 \\ \vdots & \vdots & & \vdots \\ 0 & 0 & \cdots & d_m \end{bmatrix} ; E=\begin{bmatrix} e_1 & 0 & \cdots & 0 \\ 0 & e_2 & \cdots & 0 \\ \vdots & \vdots & & \vdots \\ 0 & 0 & \cdots & e_n \end{bmatrix}$$

ក. គណនា $DA$ និង $AE$

ខ. កំណត់ជួរដេកនៃ $DA$ និងជួរឈរនៃ $AE$ រួចទាញរកវិធានពីរយ៉ាងសម្រាប់ធ្វើប្រមាណវិធីគុណលើម៉ាទ្រីសអង្កត់ទ្រូងមួយ ។

គ. គណនា $AB$ និង $BA$ ដោយប្រើវិធានដែលបាននៅក្នុងសំណួរ ខ ដែល

$$A=\begin{bmatrix} -2 & 1 & 5 \\ 3 & 0 & 2 \\ -7 & 1 & 5 \end{bmatrix} \text{ និង } B=\begin{bmatrix} 4 & 0 & 0 \\ 0 & 1 & 0 \\ 0 & 0 & -3 \end{bmatrix}$$

៨. ដោះស្រាយសមីការម៉ាទ្រីសរក $a,b,c$ និង $d$ បើ $\begin{bmatrix} a-b & b+c \\ 3d+c & 2a-4d \end{bmatrix}=\begin{bmatrix} 8 & 1 \\ 7 & 6 \end{bmatrix}$ ។

៩. គណនាដេទែមីណង់នៃម៉ាទ្រីសខាងក្រោម៖

ក. $\begin{bmatrix} 3 & 5 \\ -2 & 4 \end{bmatrix}$ ខ. $\begin{bmatrix} 3 & -17 & 4 \\ 0 & 5 & 1 \\ 0 & 0 & -2 \end{bmatrix}$ គ. $\begin{bmatrix} 1 & -3 & 0 \\ -1 & 4 & 1 \\ 5 & -2 & 2 \end{bmatrix}$

ឃ. $\begin{bmatrix} 1 & 0 & 0 & 3 \\ 2 & 7 & 0 & 6 \\ 0 & 6 & 3 & 0 \\ 7 & 3 & 1 & -5 \end{bmatrix}$ ង. $\begin{bmatrix} -2 & 7 & 6 \\ 5 & 1 & -2 \\ 3 & 8 & 4 \end{bmatrix}$ ច. $\begin{bmatrix} a-3 & 5 \\ -3 & a-2 \end{bmatrix}$

១០. គេមានម៉ាទ្រីសពីរគឺ $A=\begin{bmatrix} -5 & 0 & 2 \\ 6 & 1 & 2 \\ 2 & 3 & 1 \end{bmatrix}$ និង $B=\begin{bmatrix} -5 & 6 & 2 \\ 0 & 1 & 3 \\ 2 & 2 & 1 \end{bmatrix}$

ចូរគណនាដេទែមីណង់នៃម៉ាទ្រីសទាំងពីរតាម *Cofactor* ក្នុងករណីខាងក្រោម៖

ក. ជួរដេកទី១ ខ. ជួរឈរទី១

១១. គេមានម៉ាទ្រីសបីដូចខាងក្រោម ៖

$A=\begin{bmatrix} 2 & -4 \\ 1 & 3 \\ 6 & -3 \end{bmatrix}$ , $B=\begin{bmatrix} 7 & -3 & 2 \\ 1 & -2 & 3 \\ -1 & 6 & 5 \end{bmatrix}$ , $C=\begin{bmatrix} 2 & -1 & 3 \\ 1 & 2 & 4 \\ 5 & -3 & 6 \end{bmatrix}$

ក. ចូរត្រង់ស្ប៉ូនៃម៉ាទ្រីសទាំងបីនេះ ។

ខ. បង្ហាញថា $det(B)=det(B^T)$ និង $det(C)=det(C^T)$

១២. គេឲ្យម៉ាទ្រីស $A$ មានលំដាប់ $3\times3$ ដែល $\det(A)=-7$, ដែលម៉ាទ្រីស $A$ កំណត់ដូចខាងក្រោម $A=\begin{bmatrix} a & b & c \\ d & e & f \\ g & h & i \end{bmatrix}$ ។

ចូរគណនា

ក. $a)\ det(3A)$ , $b)\ 3det(A)$ , $c)\ det(2A^{-1})$ , $d)\ det((2A)^{-1})$

ខ. ធ្វើការសន្និដ្ឋានចំពោះ $a)$ និង $b)$ រួចចំពោះ $c)$ និង $d)$

១៣. គេឲ្យម៉ាទ្រីស $A=\begin{bmatrix} 1 & -2 & 3 \\ 6 & 7 & -1 \\ -3 & 1 & 4 \end{bmatrix}$ ។

ក. គណនា *Minors* ទាំងអស់នៃ $A$

ខ. គណនា *Cofactors* ទាំងអស់នៃ $A$

១៤. គេឲ្យម៉ាទ្រីស $E=\begin{bmatrix}1&3&1&1\\2&5&2&2\\1&3&8&9\\1&3&2&2\end{bmatrix}$ ។ ចូរគណនា $adj(E)$ និង $E^{-1}$ ។

១៥. គេឲ្យម៉ាទ្រីស $F=\begin{bmatrix}2&-1&1\\4&1&-3\\2&-1&3\end{bmatrix}$ ។ គណនា $\det(F)$ និង $\det(F^{-1})$ ។

១៦. ចូររក $adj(A)$ ដោយដឹងថា $A=\begin{bmatrix}\lambda_1&0&0&\cdots&0\\0&\lambda_2&0&\cdots&0\\\vdots&\vdots&\vdots&&\vdots\\0&0&0&\cdots&\lambda_n\end{bmatrix}$ , $\lambda\neq 0$ , $i=1,2,...,n$

១៧. រកតម្លៃ $\lambda$ ដើម្បីឲ្យ $det(A)=0$

ក. $A=\begin{bmatrix}\lambda-2&1\\-5&\lambda+4\end{bmatrix}$ ខ. $A=\begin{bmatrix}\lambda-2&0&0\\0&\lambda&2\\0&3&\lambda-1\end{bmatrix}$

១៨. គេមានម៉ាទ្រីស $A=\begin{bmatrix}3&1&2\\0&1&1\\-1&1&0\end{bmatrix}$ ចូរបង្ហាញថា $adj(A).A=(det(A)).I$ ។

១៩. បង្ហាញថាម៉ាទ្រីស $A=\begin{bmatrix}cos\theta&sin\theta&0\\-sin\theta&cos\theta&0\\0&0&1\end{bmatrix}$ មានចម្រាសចំពោះគ្រប់តម្លៃ $\theta$ ។

រួចគណនា $A^{-1}$ ដោយប្រើរូបមន្ត $A^{-1}=\dfrac{1}{\det(A)}adj(A)$ ។

២០. ដោយប្រើវិធានក្រាម័រ ចូររកមុំ $\theta,\beta,\gamma$ ដែល $0\le\theta\le2\pi, 0\le\beta\le2\pi, 0\le\gamma\le2\pi$ នៃប្រព័ន្ធសមីការខាងក្រោម ៖

$$\begin{cases}2sin\theta-cos\beta+3tan\gamma=3\\4sin\theta+2cos\beta-2tan\gamma=2\\6sin\theta-3cos\beta+tan\gamma=9\end{cases}$$

២១. ចំពោះត្រីកោណក្នុងរូបដោយប្រើត្រីកោណមាត្រចូរបង្ហាញថា៖

a) $$\begin{cases}bcos\gamma+c\,cos\beta=a\\c\,cos\alpha+acos\gamma=b\\acos\beta+bcos\alpha=c\end{cases}$$




b) ដោយប្រើវិធានក្រាម័រ បង្ហាញថា $\cos\alpha=\dfrac{b^2+c^2-a^2}{2bc}$

រួចទាញរករូបមន្តចំពោះ $\cos\beta$ និង $\cos\gamma$ ដោយប្រើវិធានក្រាម័រ ។

២២. ចូរកំណត់តម្លៃ $k$ ដើម្បីឲ្យប្រព័ន្ធសមីការខាងក្រោមមាន ចម្លើយតែមួយគត់, គ្មានចម្លើយ និង ចម្លើយរាប់មិនអស់

ក. $\begin{cases} x+y-z=1 \\ 2x+3y+kz=3 \\ x+ky+3z=2 \end{cases}$ ខ. $\begin{cases} x \quad -3z=-3 \\ 2x+ky-z=-2 \\ x+2y+kz=1 \end{cases}$

២៣. $a)$ បង្ហាញថា ចំពោះម៉ាទ្រីសការេ $A$ និង $B$ គេបានសមភាព

$(A+B)^2=A^2+2AB+B^2$ លុះត្រាតែ $AB=BA$ ។

$b)$ បង្ហាញថា $A^2=4A-I$ ហើយទាញរក $A^4=56A-15I$ ។

ផ្ទៀងផ្ទាត់សមីការចុងក្រោយនេះទៅនឹងការគណនាដោយផ្ទាល់នៃ $A^4$ ។

២៤. ចូរពិនិត្យមើលម៉ាទ្រីសខាងក្រោម:

$$A=\begin{bmatrix} 1 & 2 & 1 \\ 3 & 1 & 4 \\ 2 & 3 & 1 \end{bmatrix},\ B=\begin{bmatrix} 2 & 3 & 1 \\ 3 & 1 & 4 \\ 1 & 2 & 1 \end{bmatrix},\ C=\begin{bmatrix} 1 & 2 & 1 \\ 7 & 7 & 6 \\ 2 & 3 & 1 \end{bmatrix}$$ ។

ចូររកម៉ាទ្រីសងាយៗ $E_1,E_2,E_3$ និង $E_4$ ដែល $E_1A=B$ , $E_2B=A$ , $E_3A=C$ , $E_4C=A$

រកម៉ាទ្រីសច្រាសនៃ $E_1,E_2,E_3$ និង $E_4$ ។

២៥. គេមានម៉ាទ្រីស $A$ លំដាប់ $3\times3$ ដែល $A=\begin{bmatrix} 0 & 1 & 0 \\ 1 & 0 & 1 \\ 0 & 1 & 0 \end{bmatrix}$ ។ គណនា $A^2$ ហើយនឹង $A^3$

រួចបង្ហាញថា $A^3=2A$ ។ ទាញចេញពីសមីការនេះ ថា $A$ គ្មានច្រាស ។

២៦. រកម៉ាទ្រីសដែលមានលំដាប់ $2\times2$ , $A$ មួយដែល $A^2=O_{2\times2}$ ប៉ុន្តែ $A\neq 0_{2\times2}$ ទេ ។

២៧. គេមានស្វ៊ីត Fibonacci កំណត់ដោយទំនាក់ $f_0=1, f_1=1, f_{n+1}=f_n+f_{n-1}$ ដែល $n\geq1$ ។

$a)$ ចូររកតម្លៃ $f_2,f_3,\ldots,f_{10}$ ។

$b)$ តាង $A=\begin{bmatrix} 0 & 1 \\ 1 & 1 \end{bmatrix}$ ហើយ $X_n=\begin{bmatrix} f_{n-1} \\ f_n \end{bmatrix}$ ចំពោះ $n\geq1$ ។ បង្ហាញថា $AX_n=X_{n+1}$

ចំពោះ $n\geq1$ និង បង្ហាញថា $A^nX_1=X_{n+1}$ ។

$c)$ គណនា $A^2,A^3,A^5$ ហើយ $A^5X_1=X_6$ ដើម្បីរក $f_6$ ។ ចូរផ្ទៀងផ្ទាត់ចម្លើយរបស់អ្នកទៅនឹងលទ្ធផលរបស់អ្នកនៅក្នុងលំហាត់ $a)$ ។

២៨. គេអោយ $A$ ជាម៉ាទ្រីសការេលំដាប់ $3\times2$ ដែលកំណត់ដោយ $A=\begin{bmatrix} 1 & 2 \\ 3 & 4 \\ -1 & 4 \end{bmatrix}$ ។

ចូររកគ្រប់ម៉ាទ្រីស $B$ ដែល $BA=I$ , $I$ ជាម៉ាទ្រីសការេលំដាប់ $2$ ។

២៩. គេអោយ $A$ ជាម៉ាទ្រីសការេលំដាប់ $2\times 2$ ដែល $A=\begin{bmatrix} a & 0 \\ b & a \end{bmatrix}$ ហើយ $a,b\in\mathbb{R}$ ។

យើងហៅថា $I$ និង $J$ ជាម៉ាទ្រីសដែល $I=\begin{bmatrix} 1 & 0 \\ 0 & 1 \end{bmatrix}$ និង $J=\begin{bmatrix} 0 & 0 \\ 0 & 0 \end{bmatrix}$ ។

$a)$ គណនា $A^2$ ។

$b)$ គណនា $A^2-2aA+a^2$ ។

$c)$ ចូរសរសេរ $A$ ជាអនុគមន៍នៃ $a,I$ និង $b$ ។ គណនា $A^n$ ជាអនុគមន៍នៃ $n$ ( $n$ ជាចំនួនគត់ធម្មជាតិ ) ។

៣០. គេមានម៉ាទ្រីស $A$ មានទម្រង់ $(m,n)$ មានមេគុណជាចំនួនពិត ។ យើងហៅសញ្ញាសម្គាល់ $A^T$ ជាម៉ាទ្រីសត្រង់ស្ប៉ូនៃ $A$ ។ ឧបមាម៉ាទ្រីស $X$ មួយដែលផ្ទៀងផ្ទាត់ ទំនាក់ទំនង

$$\begin{cases} AXA=A & (1) \\ (XA)^T=XA & (2) \end{cases}$$

$a)$ រកវិមាត្ររបស់ម៉ាទ្រីស $X$ ។

$b)$ បង្ហាញថាសំណុំលក្ខណៈ $(1)$ និង $(2)$ សមមូលនឹងលក្ខណៈ $(3): X^TAX=A^T$ ។

៣១. រកគ្រប់ម៉ាទ្រីស $A$ ដែលជាម៉ាទ្រីសការេលំដាប់ $2\times 2$ ដែលផ្ទៀងផ្ទាត់ $A^2=A$ ។

៣២. ពិនិត្យម៉ាទ្រីស $M=\begin{bmatrix} 0 & c & -b \\ -c & 0 & a \\ b & -a & 0 \end{bmatrix}$ ដែល $a,b,c\in\mathbb{R}$ ។

$a)$ រកទំនាក់ទំនងរវាង $M^3$ និង $M$ ។

$b)$ តាង $\delta$ ជាចំនួនពិតមិនសូន្យ ។ បង្ហាញថាម៉ាទ្រីស $(\delta I+M)$ និង $(\delta I-M)$ មានម៉ាទ្រីសច្រាស ។

$c)$ ឧបមាថា $N=(\delta I+M)^{-1}(\delta I-M)$ ។ បង្ហាញថា $N$ មានចម្រាសហើយចម្រាសនោះគឺ $N^{-1}=N^T$ ។

# ផ្នែកដំណោះស្រាយ

១. គណនាកន្សោមខាងក្រោមបើអាចធ្វើបាន:

យើងមាន

$$A=\begin{bmatrix}3 & 0\\ -1 & 2\\ 1 & 1\end{bmatrix};\ B=\begin{bmatrix}4 & -1\\ 0 & 2\end{bmatrix};\ C=\begin{bmatrix}1 & 4 & 2\\ 3 & 1 & 5\end{bmatrix};\ D=\begin{bmatrix}1 & 5 & 2\\ -1 & 0 & 1\\ 3 & 2 & 4\end{bmatrix};\ E=\begin{bmatrix}6 & 1 & 3\\ -1 & 1 & 2\\ 4 & 1 & 3\end{bmatrix}$$

ក. $A+D=\begin{bmatrix}1 & 5 & 2\\ -1 & 0 & 1\\ 3 & 2 & 4\end{bmatrix}+\begin{bmatrix}6 & 1 & 3\\ -1 & 1 & 2\\ 4 & 1 & 3\end{bmatrix}=\begin{bmatrix}1+6 & 5+1 & 2+3\\ -1-1 & 0+1 & 1+2\\ 3+4 & 2+1 & 4+3\end{bmatrix}=\begin{bmatrix}7 & 6 & 5\\ -2 & 1 & 3\\ 7 & 3 & 7\end{bmatrix}$

ខ. $D-E=\begin{bmatrix}1 & 5 & 2\\ -1 & 0 & 1\\ 3 & 2 & 4\end{bmatrix}-\begin{bmatrix}6 & 1 & 3\\ -1 & 1 & 2\\ 4 & 1 & 3\end{bmatrix}=\begin{bmatrix}1-6 & 5-1 & 2-3\\ -1-(-1) & 0-1 & 1-2\\ 3-4 & 2-1 & 4-3\end{bmatrix}=\begin{bmatrix}-5 & 4 & -1\\ 0 & -1 & -1\\ -1 & 1 & 1\end{bmatrix}$

គ. $5A=5\begin{bmatrix}3 & 0\\ -1 & 2\\ 1 & 1\end{bmatrix}=\begin{bmatrix}5\times3 & 5\times0\\ 5\times(-1) & 5\times2\\ 5\times1 & 5\times1\end{bmatrix}=\begin{bmatrix}15 & 0\\ -5 & 10\\ 5 & 5\end{bmatrix}$

ឃ. $-7C=-7\begin{bmatrix}1 & 4 & 2\\ 3 & 1 & 5\end{bmatrix}=\begin{bmatrix}-7\times1 & -7\times4 & -7\times2\\ -7\times3 & -7\times1 & -7\times5\end{bmatrix}=\begin{bmatrix}-7 & -28 & -14\\ -21 & -7 & -35\end{bmatrix}$

ង. $2B-C$ មិនអាចកំណត់បាន

ច. $4E-2D=4\begin{bmatrix}6 & 1 & 3\\ -1 & 1 & 2\\ 4 & 1 & 3\end{bmatrix}-2\begin{bmatrix}1 & 5 & 2\\ -1 & 0 & 1\\ 3 & 2 & 4\end{bmatrix}=\begin{bmatrix}24 & 4 & 12\\ -4 & 4 & 8\\ 16 & 4 & 12\end{bmatrix}-\begin{bmatrix}2 & 10 & 4\\ -2 & 0 & 2\\ 6 & 4 & 8\end{bmatrix}$

$$=\begin{bmatrix}22 & -6 & 8\\ -2 & 4 & 6\\ 10 & 0 & 4\end{bmatrix}$$

ឆ. $-3(D+2E)=-3D-6E=-3\begin{bmatrix}1 & 5 & 2\\ -1 & 0 & 1\\ 3 & 2 & 4\end{bmatrix}-6\begin{bmatrix}6 & 1 & 3\\ -1 & 1 & 2\\ 4 & 1 & 3\end{bmatrix}$

$$=\begin{bmatrix}-3 & -15 & -6\\ 3 & 0 & -3\\ -9 & -6 & -12\end{bmatrix}+\begin{bmatrix}-36 & -6 & -18\\ 6 & -6 & -12\\ -24 & -6 & -18\end{bmatrix}=\begin{bmatrix}-39 & -21 & -24\\ 9 & -6 & -15\\ -33 & -12 & -30\end{bmatrix}$$

ជ. $A-A=\begin{bmatrix}3 & 0\\ -1 & 2\\ 1 & 1\end{bmatrix}-\begin{bmatrix}3 & 0\\ -1 & 2\\ 1 & 1\end{bmatrix}=\begin{bmatrix}0 & 0\\ 0 & 0\\ 0 & 0\end{bmatrix}$

២. ដោះស្រាយប្រព័ន្ធសមីការលីនេអ៊ែរខាងក្រោមតាមរូបមន្តក្រាមែរ ( *Gramer's Rule*)

ក. $\begin{cases} 3x-y=1 \\ x+2y=0 \end{cases}$ គេបាន $D=\begin{vmatrix} 3 & -1 \\ 1 & 2 \end{vmatrix}=6-(-1)=7$ , $D_x=\begin{vmatrix} 1 & -1 \\ 0 & 2 \end{vmatrix}=2-0=2$

$D_y=\begin{vmatrix} 3 & 1 \\ 1 & 0 \end{vmatrix}=0-1=-1$ នាំឲ្យ $x=\dfrac{D_x}{D}=\dfrac{2}{7}$ , $y=\dfrac{D_y}{D}=\dfrac{-1}{7}$

ដូចនេះ $x=\dfrac{2}{7}$ , $y=\dfrac{-1}{7}$ ជាគូចម្លើយនៃប្រព័ន្ធសមីការ ។

ខ. $\begin{cases} 4x-3y=2 \\ 3x+4y=5 \end{cases}$ គេបាន $D=\begin{vmatrix} 4 & -3 \\ 3 & 4 \end{vmatrix}=16-(-9)=25$

$D_x=\begin{vmatrix} 2 & -3 \\ 5 & 4 \end{vmatrix}=8-(-15)=23$ , $D_y=\begin{vmatrix} 4 & 2 \\ 3 & 5 \end{vmatrix}=20-6=14$

នាំឲ្យ $x=\dfrac{D_x}{D}=\dfrac{23}{25}$ , $y=\dfrac{D_y}{D}=\dfrac{14}{25}$

ដូចនេះ $x=\dfrac{23}{25}$ , $y=\dfrac{14}{25}$ ជាគូចម្លើយនៃប្រព័ន្ធសមីការ ។

គ. $\begin{cases} x-17y+18z=2 \\ 19x-18y-z=0 \\ x+3y-2z=2 \end{cases}$ \

គេបាន $D=\begin{vmatrix} 1 & -17 & 18 \\ 19 & -18 & -1 \\ 1 & 3 & -2 \end{vmatrix}=36+17+1026-(-324)-646-(-3)=760$

$D_x=\begin{vmatrix} 2 & -17 & 18 \\ 0 & -18 & -1 \\ 2 & 3 & -2 \end{vmatrix}=72+34+0-(-648)-0-(-6)=760$

$D_y=\begin{vmatrix} 1 & 2 & 18 \\ 19 & 0 & -1 \\ 1 & 2 & -2 \end{vmatrix}=0+(-2)+684-0-(-76)-(-2)=760$

$D_z=\begin{vmatrix} 1 & -17 & 2 \\ 19 & -18 & 0 \\ 1 & 3 & 2 \end{vmatrix}=-36+0+114-(-36)-(-646)-0=760$

នាំឲ្យ $x=\dfrac{D_x}{D}=\dfrac{760}{760}=1, y=\dfrac{D_y}{D}=\dfrac{760}{760}=1, z=\dfrac{D_z}{D}=\dfrac{760}{760}=1$

ដូចនេះ $x=1, y=1, z=1$ ជាចម្លើយនៃប្រព័ន្ធសមីការលីនេអ៊ែរ ។

ឃ. $\begin{cases} x+y+z=4 \\ x+2y+z=5 \\ x-y=-1 \end{cases}$ គេបាន $D=\begin{vmatrix} 1 & 1 & 1 \\ 1 & 2 & 1 \\ 1 & -1 & 0 \end{vmatrix}=0+1+(-1)-2-0-(-1)=-1$

$$D_x=\begin{vmatrix} 4 & 1 & 1 \\ 5 & 2 & 1 \\ -1 & -1 & 0 \end{vmatrix}=0+(-1)+(-5)-(-2)-0-(-4)=0$$

$$D_y=\begin{vmatrix} 1 & 4 & 1 \\ 1 & 5 & 1 \\ 1 & -1 & 0 \end{vmatrix}=0+4+(-1)-5-0-(-1)=-1$$

$$D_z=\begin{vmatrix} 1 & 1 & 4 \\ 1 & 2 & 5 \\ 1 & -1 & -1 \end{vmatrix}=-2+5+(-4)-8-(-1)-(-5)=-3$$

នាំឲ្យ $x=\frac{D_x}{D}=\frac{0}{-1}=0, y=\frac{D_y}{D}=\frac{-1}{-1}=1, z=\frac{D_z}{D}=\frac{-3}{-1}=3$

ដូចនេះ: $x=0, y=1, z=3$ ជាចម្លើយនៃប្រព័ន្ធសមីការលីនេអ៊ែរ ។

ង. $\begin{cases} x+3y+2z=2 \\ x+4y+3z=3 \\ 2x+7y+6z=8 \end{cases}$ គេបាន $D=\begin{vmatrix} 1 & 3 & 2 \\ 1 & 4 & 3 \\ 2 & 7 & 6 \end{vmatrix}=24+18+14-16-18-21=1$

$$D_x=\begin{vmatrix} 2 & 3 & 2 \\ 3 & 4 & 3 \\ 8 & 7 & 6 \end{vmatrix}=48+72+42-64-54-42=2$$

$$D_y=\begin{vmatrix} 1 & 2 & 2 \\ 1 & 3 & 3 \\ 2 & 8 & 6 \end{vmatrix}=18+12+16-12-12-24=-2$$

$$D_z=\begin{vmatrix} 1 & 3 & 2 \\ 1 & 4 & 3 \\ 2 & 7 & 8 \end{vmatrix}=32+18+14-16-24-21=3$$

នាំឲ្យ $x=\frac{D_x}{D}=\frac{2}{1}=2, y=\frac{D_y}{D}=\frac{-2}{1}=-2, z=\frac{D_z}{D}=\frac{3}{1}=3$

ដូចនេះ: $x=2, y=-2, z=3$ ជាចម្លើយនៃប្រព័ន្ធសមីការលីនេអ៊ែរ ។

ច. $\begin{cases} 2x+6y-4z=1 \\ x+3y-2z=4 \\ 2x+y-3z=-7 \end{cases}$

គេបាន $D=\begin{vmatrix} 2 & 6 & -4 \\ 1 & 3 & -2 \\ 2 & 1 & -3 \end{vmatrix}=-18-24-4+24+18+4=0$

$D_x=\begin{vmatrix} 1 & 6 & -4 \\ 4 & 3 & -2 \\ -7 & 1 & -3 \end{vmatrix}=-9+84-16-84+72+2=49$

$D_y=\begin{vmatrix} 2 & 1 & -4 \\ 1 & 4 & -2 \\ 2 & -7 & -3 \end{vmatrix}=-24-4+28+32+3-28=7$

$D_z=\begin{vmatrix} 2 & 6 & 1 \\ 1 & 3 & 4 \\ 2 & 1 & -7 \end{vmatrix}=-42+48+1-6+42-8=35$

ដោយ $D=0, D_x\neq 0, D_y\neq 0, D_z\neq 0$

ដូចនេះ: ប្រព័ន្ធសមីការគ្មានចម្លើយ ។

៣. ដោះស្រាយប្រព័ន្ធសមីការខាងក្រោមតាមរូបមន្ត *Guass Jordan*

ក. $\begin{cases} 2x-3y=-5 \\ 3x+2y=12 \end{cases} c$

គេបាន $\left[\begin{array}{cc|c} 2 & -3 & -5 \\ 3 & 2 & 12 \end{array}\right]$

$\left[\begin{array}{cc|c} 1 & -3/2 & -5/2 \\ 3 & 2 & 12 \end{array}\right] \quad L_1\to 1/2L_1$

$\left[\begin{array}{cc|c} 1 & -3/2 & -5/2 \\ 0 & 13/2 & 39/2 \end{array}\right] \quad L_2\to -3L_1+L_2$

$\left[\begin{array}{cc|c} 1 & -3/2 & -5/2 \\ 0 & 1 & 3 \end{array}\right] \quad L_2\to 2/13L_2$

$\left[\begin{array}{cc|c} 1 & 0 & 2 \\ 0 & 1 & 3 \end{array}\right] \quad L_1\to L_1+3/2L_2$

ដូចនេះ: $x=2, y=3$ ជាចម្លើយនៃប្រព័ន្ធសមីការលីនេអ៊ែរ ។

ខ. $\begin{cases} x-2y-3z=-1 \\ 2x+y+z=6 \\ x+3y-2z=13 \end{cases}$

គេបាន $\left[\begin{array}{ccc|c} 1 & -2 & -3 & -1 \\ 2 & 1 & 1 & 6 \\ 1 & 3 & -2 & 13 \end{array}\right]$

$\left[\begin{array}{ccc|c} 1 & -2 & -3 & -1 \\ 0 & 5 & 7 & 8 \\ 0 & 5 & 1 & -6 \end{array}\right] \quad \begin{array}{l} L_2 \to L_2 - 2L_1 \\ L_3 \to L_3 - L_1 \end{array}$

$\left[\begin{array}{ccc|c} 1 & -2 & -3 & -1 \\ 0 & 5 & 7 & 8 \\ 0 & 0 & 6 & -6 \end{array}\right] \quad L_3 \to L_2 - L_3$

$\left[\begin{array}{ccc|c} 1 & -2 & -3 & -1 \\ 0 & 5 & 7 & 8 \\ 0 & 0 & 1 & -1 \end{array}\right] \quad L_3 \to 1/6\, L_3$

$\left[\begin{array}{ccc|c} 1 & -2 & 0 & -4 \\ 0 & 5 & 0 & 15 \\ 0 & 0 & 1 & -1 \end{array}\right] \quad \begin{array}{l} L_1 \to L_1 + 3L_3 \\ L_2 \to L_2 - 7L_3 \end{array}$

$\left[\begin{array}{ccc|c} 1 & -2 & 0 & -4 \\ 0 & 1 & 0 & 3 \\ 0 & 0 & 1 & -1 \end{array}\right] \quad L_2 \to 1/5\, L_2$

$\left[\begin{array}{ccc|c} 1 & 0 & 0 & 2 \\ 0 & 1 & 0 & 3 \\ 0 & 0 & 1 & -1 \end{array}\right] \quad L_1 \to L_1 + 2L_2$

ដូចនេះ $x=2, y=3, z=-1$ ជាចម្លើយនៃប្រព័ន្ធសមីការលីនេអ៊ែរ ។

គ. $\begin{cases} x-2y+3z=1 \\ x-y-7z=-4 \\ 2x+4y+9z=-9 \end{cases}$

គេបាន $\left[\begin{array}{ccc|c} 1 & -2 & 3 & 1 \\ 1 & -1 & 7 & -4 \\ 2 & 4 & 9 & -9 \end{array}\right]$

$$\left[\begin{array}{ccc|c} 1 & -2 & 3 & 1 \\ 0 & -1 & -4 & 5 \\ 0 & 8 & 3 & -11 \end{array}\right] \quad \begin{array}{l} \\ L_2 \to L_1 - L_2 \\ L_3 \to L_3 - 2L_1 \end{array}$$

$$\left[\begin{array}{ccc|c} 1 & -2 & 3 & 1 \\ 0 & -1 & -4 & 5 \\ 0 & 0 & -29 & 29 \end{array}\right] \quad L_3 \to L_3 + 8L_1$$

$$\left[\begin{array}{ccc|c} 1 & -2 & 3 & 1 \\ 0 & -1 & -4 & 5 \\ 0 & 0 & -1 & 1 \end{array}\right] \quad L_3 \to 1/29\, L_3$$

$$\left[\begin{array}{ccc|c} 1 & -2 & 0 & 4 \\ 0 & -1 & 0 & 1 \\ 0 & 0 & 1 & -1 \end{array}\right] \quad \begin{array}{l} L_1 \to L_1 - 3L_3 \\ L_2 \to L_2 + 4L_3 \\ \end{array}$$

$$\left[\begin{array}{ccc|c} 1 & -2 & 0 & 4 \\ 0 & 1 & 0 & -1 \\ 0 & 0 & 1 & -1 \end{array}\right] \quad L_2 \to -L_2$$

$$\left[\begin{array}{ccc|c} 1 & 0 & 0 & 4 \\ 0 & 1 & 0 & -1 \\ 0 & 0 & 1 & -1 \end{array}\right] \quad L_1 \to L_1 + 2L_2$$

ដូចនេះ: $x = 2, y = -1, z = -1$ ជាចម្លើយនៃប្រព័ន្ធសមីការលីនេអ៊ែរ ។

ឃ. $\begin{cases} x + y + z = 1 \\ x + 2y - 2z = 0 \\ 2x + 3y - z = 5 \end{cases}$ គេបាន $\left[\begin{array}{ccc|c} 1 & 1 & 1 & 1 \\ 1 & 2 & -2 & 0 \\ 2 & 3 & -1 & 5 \end{array}\right]$

$$\left[\begin{array}{ccc|c} 1 & 1 & 1 & 1 \\ 0 & -1 & 3 & 1 \\ 0 & 1 & -3 & 3 \end{array}\right] \quad \begin{array}{l} \\ L_2 \to L_2 - L_1 \\ L_3 \to L_3 - 2L_1 \end{array}$$

$$\left[\begin{array}{ccc|c} 1 & 1 & 1 & 1 \\ 0 & -1 & 3 & 1 \\ 0 & 0 & 0 & 4 \end{array}\right] \quad L_3 \to L_3 + L_2$$

ដោយ $0x + 0y + 0z = 4$ មិនផ្ទៀងផ្ទាត់ចំពោះគ្រប់តម្លៃ $x, y, z$

ដូចនេះ: ប្រព័ន្ធសមីការគ្មានចម្លើយ ។

ង. $\begin{cases} 2x+y+z=0 \\ x-2y-2z=0 \\ x+y+z=0 \end{cases}$

គេបាន $\left[\begin{array}{ccc|c} 2 & 1 & 1 & 0 \\ 1 & -2 & -2 & 0 \\ 1 & 1 & 1 & 0 \end{array}\right]$

$\left[\begin{array}{ccc|c} 2 & 1 & 1 & 0 \\ 0 & 5 & 5 & 0 \\ 0 & 3 & 3 & 0 \end{array}\right]$ $\begin{matrix} L_2 \to L_1 - 2L_2 \\ L_3 \to L_3 - L_2 \end{matrix}$

$\left[\begin{array}{ccc|c} 2 & 1 & 1 & 0 \\ 0 & 1 & 1 & 0 \\ 0 & 1 & 1 & 0 \end{array}\right]$ $\begin{matrix} L_2 \to 1/5\,L_2 \\ L_3 \to 1/3\,L_3 \end{matrix}$

$\left[\begin{array}{ccc|c} 2 & 1 & 1 & 0 \\ 0 & 1 & 1 & 0 \\ 0 & 0 & 0 & 0 \end{array}\right]$ $L_3 \to L_3 - L_2$

$\left[\begin{array}{ccc|c} 2 & 0 & 0 & 0 \\ 0 & 1 & 1 & 0 \\ 0 & 0 & 0 & 0 \end{array}\right]$ $L_1 \to L_1 - L_2$

$\left[\begin{array}{ccc|c} 1 & 0 & 0 & 0 \\ 0 & 1 & 1 & 0 \\ 0 & 0 & 0 & 0 \end{array}\right]$ $L_1 \to 1/2\,L_1$

ដោយ $0x+0y+0z=0$ សមីការផ្ទៀងផ្ទាត់ចំពោះគ្រប់តម្លៃ $x, y, z$

គេបាន ប្រព័ន្ធសមីការមានចម្លើយរាប់មិនអស់

ដោយ $\begin{cases} x \qquad\qquad = 0 \\ \qquad y+z \;= 0 \\ 0x+0y+0z=0 \end{cases}$ តាង $z=t \;, t \in IR$

គេបាន $y+z=0 \Rightarrow y=-z=-t$

ដូចនេះ

| គេបាន $x=0, y=-t, z=t \;, t \in IR$ ជាចម្លើយនៃប្រព័ន្ធសមីការ ។ |
|---|

ច. $\begin{cases} a+2b-c-3d=2 \\ 3a+b-2c-d=6 \\ a+b+3c-2d=-3 \\ -2a-2b+3c+d=-9 \end{cases}$

គេបាន $\left[\begin{array}{cccc|c} 1 & 2 & -1 & -3 & 2 \\ 3 & 1 & -2 & -1 & 6 \\ 1 & 1 & 3 & -2 & -3 \\ -2 & -2 & 3 & 1 & -9 \end{array}\right]$

$$\left[\begin{array}{cccc|c} 1 & 2 & -1 & -3 & 2 \\ 0 & -5 & 1 & 8 & 0 \\ 0 & 1 & -4 & -1 & 5 \\ 0 & 2 & 1 & -5 & -5 \end{array}\right] \begin{array}{l} \\ L_2 \to L_2 - 3L_1 \\ L_3 \to L_3 - L_1 \\ L_4 \to L_4 + 2L_1 \end{array}$$

$$\left[\begin{array}{cccc|c} 1 & 2 & -1 & -3 & 2 \\ 0 & -5 & 1 & 8 & 0 \\ 0 & 1 & -4 & -1 & 5 \\ 0 & 0 & 9 & -3 & -15 \end{array}\right] \begin{array}{l} \\ \\ \\ L_4 \to L_4 - 2L_3 \end{array}$$

$$\left[\begin{array}{cccc|c} 1 & 2 & -1 & -3 & 2 \\ 0 & -5 & 1 & 8 & 0 \\ 0 & 0 & -19 & 3 & 25 \\ 0 & 0 & 3 & -1 & -5 \end{array}\right] \begin{array}{l} \\ \\ L_3 \to L_2 + 5L_3 \\ L_4 \to 1/3\, L_4 \end{array}$$

$$\left[\begin{array}{cccc|c} 1 & 2 & -1 & -3 & 2 \\ 0 & -5 & 1 & 8 & 0 \\ 0 & 0 & -19 & 3 & 25 \\ 0 & 0 & 0 & -10 & -20 \end{array}\right] \begin{array}{l} \\ \\ \\ L_4 \to 19L_4 + 3L_3 \end{array}$$

$$\left[\begin{array}{cccc|c} 1 & 2 & -1 & -3 & 2 \\ 0 & -5 & 1 & 8 & 0 \\ 0 & 0 & -19 & 3 & 25 \\ 0 & 0 & 0 & 1 & 2 \end{array}\right] \begin{array}{l} \\ \\ \\ L_4 \to -1/10\, L_4 \end{array}$$

$$\left[\begin{array}{cccc|c} 1 & 2 & -1 & 0 & 8 \\ 0 & -5 & 1 & 0 & -16 \\ 0 & 0 & -19 & 0 & 19 \\ 0 & 0 & 0 & 1 & 2 \end{array}\right] \begin{array}{l} L_1 \to L_1 + 3L_4 \\ L_2 \to L_2 - 8L_4 \\ L_3 \to L_3 - 3L_4 \\ \\ \end{array}$$

$$\left[\begin{array}{cccc|c} 1 & 2 & -1 & 0 & 8 \\ 0 & -5 & 1 & 0 & -16 \\ 0 & 0 & 1 & 0 & -1 \\ 0 & 0 & 0 & 1 & 2 \end{array}\right] \begin{array}{l} \\ \\ L_3 \to -1/19\, L_3 \\ \\ \end{array}$$

$$\left[\begin{array}{cccc|c}1 & 2 & 0 & 0 & 7\\0 & 5 & 0 & 0 & 15\\0 & 0 & 1 & 0 & -1\\0 & 0 & 0 & 1 & 2\end{array}\right]\begin{array}{l}L_1\to L_1+L_3\\L_2\to L_3-L_2\\L_3\to -1/19\,L_3\\ \end{array}$$

$$\left[\begin{array}{cccc|c}1 & 2 & 0 & 0 & 7\\0 & 1 & 0 & 0 & 3\\0 & 0 & 1 & 0 & -1\\0 & 0 & 0 & 1 & 2\end{array}\right]\ L_2\to 1/5\,L_2$$

$$\left[\begin{array}{cccc|c}1 & 0 & 0 & 0 & 1\\0 & 1 & 0 & 0 & 3\\0 & 0 & 1 & 0 & -1\\0 & 0 & 0 & 1 & 2\end{array}\right]\begin{array}{l}L_1\to L_1-2L_2\\ \\ \\ \\ \end{array}$$

ដូចនេះ $a=1,b=3,c=-1,d=2$ ជាចម្លើយនៃប្រព័ន្ធសមីការលីនេអ៊ែរ ។

